# ប្រពៃណីអ្នកស្រុកចេនលា

ជីវ តាក្វាន់

## ក - យោបល់របស់អ្នកបកប្រែ

កំនត់ហេតុរបស់ ជីវ តាក្វាន់ អំពីប្រពៃណីនៃអ្នកស្រុកចេនលា ដែលមិត្តអ្នកអាន កំពុងកាន់នៅដៃនេះ ពិតជាអែកសារពិសិដ្ឋមួយនៃប្រវត្តិសាស្ត្រខ្មែរយើង។ សៀវភៅប្រវត្តិវិទ្យា រឺ អត្ថបទណាមួយដែលស្តីពីស្រុកខ្មែរ មិនដែលចន្លោះឈ្មោះអែកសារជីវ តាក្វាន់នេះឡើយ។ កូនខ្មែរគ្រប់រូបរៀនប្រវត្តិប្រទេសរបស់ខ្លួនមិនដែលនរណាមួយមិនស្គាល់ឈ្មោះ ជីវ តាក្វាន់ទេ ប៉ុន្តែការដែលយើងស្គាល់នោះ សុទ្ធតែលឺពាក្យតៗគ្នា កត់ចំលងតៗគ្នា ពីសៀវភៅមួយទៅសៀវភៅមួយ តាមរយៈសៀវភៅដើមជាភាសាបារាំងដែល លោក ប៉ូល ប៉េលិយោត បានប្រែសំរួលចេញពីអត្ថបទចិន ហើយបោះពុម្ពផ្សាយដំបូងក្នុងព្រឹត្តិបត្តនៃភាសាបារាំងនៅចុងបូព៌ា Bulletin de l' école Francaise d' Extrème-Orient (BEFEO) ពីឆ្នាំ ១៩០២ ហើយក្រោយមក ពេលដែលលោកប៉េលិយោត ទទួលមរណភាពទៅ លោក ហ្សកសឺដេស ក៏យកស្នាដៃនេះ មានទាំងអត្ថាធិប្បាយបន្ថែមក្បោះក្បាយផង ទៅបោះពុម្ពរួបរួមជាសៀវភៅមួយឡើងពី គ.ស ១៩៥១។ លោកប៉េលិយោត បានបញ្ជាក់ក្នុងអារម្ភកថា ថាលោកបានព្យាយាមបកប្រែតាមការស្រាវជ្រាវរកអែកសាររបស់ ជីវតាក្វាន់ ដែលមានលោក អាប់បែលរ៉េមុសាត់ បានប្រែផ្សាយម្តងហើយពី គ.ស ១៨១៩ ប៉ុន្តែមិនទាន់គ្រប់សព្វ។ ខ្លួនលោក បានទៅនៅប្រទេសចិនអស់ច្រើនឆ្នាំ ទើបប្រែបានជាស្នាដៃនេះ។

យើងជាខ្មែរ យើងសូមគោរព អរគុណពិសេស ចំពោះលោកអ្នកស្រាវជ្រាវជំនាញទាំងនេះ ទុកដូចជាជួយរើកកាយកំនប់ដ៏មានតំលៃមួយអោយយើងដែរ។ ប៉ុន្តែ ដោយលោកអ្នកប្រែនោះអែង មិនមែនជាខ្មែរ ម្លោះហើយយើងចេះតែមានចិត្តតូចមួយមមៃនឹកជានិច្ចថា ប្រសិនជាខ្មែរណាប្រែចេញពីអត្ថបទភាសាចិនផ្ទាល់តែម្តង យើងដូចជាអស់ចិត្តជាង ទោះបីការបកប្រែនោះមិនជ្រៅជ្រះឆ្អិនឆ្អៅណាស់ណាក៏ដោយ។

ខ្ញុំធ្លាប់បានរៀនអក្សរចិនអស់បួនឆ្នាំ កាលនៅពីក្មេង តែភ្លេចភ្លាំងទៅវិញស្ទើរគ្មានសល់ នៅចាំបានតែតួអក្សរណាធ្លាប់ប្រើញឹកញាប់ និង នៅចេះសរសេរចំលងតាមគេកើត។ ទាំងពាក្យ ទាំងអក្សរចិនមកបញ្ជាក់ផង ដូចជាឈ្មោះស្រុក ឈ្មោះរបស់ ឈ្មោះការផ្សាយជាដើម ខ្ញុំក៏ចេះតែកត់ទុកៗ នូវអក្សរចិនទាំងនោះគ្រាន់ជាអែកសារ។

សំនាងមាន នៅឆ្នាំ ១៩៦២ ខ្ញុំបានទទួលបេសកកម្មមួយខាងវប្បធម៌ អោយខ្ញុំដឹកនាំគណៈប្រតិភូអ្នកនិពន្ធខ្មែរ ទៅកាន់ប្រ

ទេសចិន។ ខ្ញុំនឹកជាប់ក្នុងចិត្តជានិច្ចថា ក្នុងដំនើរនេះ ខ្ញុំនឹងសាកសួរគេរកអែកសារស្នាដៃ ជីវ តាក្វាន់ អោយបានឃើញផ្ទាល់ភ្នែកតែម្តង បំនាច់បានមកជាន់ដីស្រុកកំនើត ជីវតាក្វាន់ហើយ។ នៅពេលដែលខ្ញុំជួបសន្ទនាជាមួយនឹងរដ្ឋមន្ត្រីក្រសួងវប្បធម៌ចិន ដែលកាលនោះជាប្រធានសមាគមអ្នកនិពន្ធចិនផងនោះ ខ្ញុំបានស្នើនឹងគេអំពីបំនងចង់ឃើញ និងចង់ចំលងអែកសារ ជីវតាក្វាន់នេះ។ រដ្ឋមន្ត្រីវប្បធម៌នោះអែង ទទួលរ៉ាប់រងបំពេញបំនងខ្ញុំ។ យប់នោះខ្ញុំអរក្រៃលែង អរបន់អោយតែភ្លឺឆាប់ នឹងបានទៅទស្សនាបណ្ណាល័យជាតិរបស់គេ តែមិនទាន់បានទៅភ្លាមទេ ព្រោះមានកម្មវិធីទៅទស្សនាទីឆ្ងាយៗពីនេះសិន។ ទាល់តែប្រាំថ្ងៃក្រោយមកទើបគេនាំខ្ញុំទៅកាន់ទីទុកអែកសារនេះ ដែលគេហៅថា ផ្នែកខាងសៀវភៅកំរ ស្ថិតនៅក្នុងបណ្ណាល័យជាតិ ក្រុងប៉េកាំង។ នាយកបណ្ណាល័យនាំសហការីគេពីរនាក់ទៀតនៅរង់ចាំខ្ញុំ គឺនាយផ្នែកខាងសៀវភៅកំរ និងអ្នកអែកទេសខាងការស្រាវជ្រាវ ប្រវត្តិចុងបូព៌ាប្រទេស ឈ្មោះ ទា សីវម៉េង អាយុ៦៩ឆ្នាំ។ គឺលោក ទា សីវម៉េង នេះហើយដែលបានរើសៀវភៅក្រាស់ៗមួយគំនរ មកចាំបង្ហាញខ្ញុំដែលសុទ្ធសឹងជាសៀវភៅមានស្តីទាក់ទងនឹងប្រវត្តិសាស្ត្រខ្មែរ ហើយសុទ្ធតែសៀវភៅដែលបោះពុម្ពតាំងពីសតវត្សទី ១៤, ១៥, ១៦ និង ១៧ មកម្ល៉េះ។ គេសន្ទនានឹងខ្ញុំយ៉ាងច្រើន ហាក់ដូចជាចង់ល្បងថា តើខ្ញុំទទួចរកអែកសារនេះ ជាអ្នកចេះដឹងខាងប្រវត្តិស្រុកទេសមែនទែន រឺ ក៏គ្រាន់តែរកៗទៅទេ? ជាភ័ព្វល្អ ខ្ញុំធ្លាប់បាន មើលអែកសារច្រើន ស្តីពីការទាក់ទងរវាងស្រុកទាំងពីរនេះ ហើយមុននឹងទៅស្រុកគេ ក៏ខ្ញុំបានកកត់ត្រាអែកសារនេះច្បាស់ៗទៀត ព្រោះបេសកកម្មខ្ញុំ ចំលើរឿងវប្បធម៌នេះអែងផងម្ល៉ោះហើយ ខ្ញុំឆ្លើយនឹងគេរហ័សហួនណាស់ រហូតគូសន្ទនាទាំងបីនាក់នោះ នាំខ្ញុំទៅជួបនឹងបណ្ឌិតសភាខាងប្រវត្តិសាស្ត្រទៀត។

ក្នុងបន្តាសៀវភៅក្រាស់ៗទាំងនេះ មានខ្លះនិយាយពីស្រុកយើងតែ ១ រឺ ២ ទំព័រប៉ុណ្ណោះទេ មានតែមួយប៉ុណ្ណោះដែលមានសេចក្តីវែងក្បោះក្បាយ គឺប្រវត្តក្នុងរាជសន្តិវង្ស ម៉ុងហ្គោល ដែលមានមួយភាគធំ និយាយពីការចាត់អ្នកកត់ត្រាមកស្រុក ចេនលា គឺលោក ជីវតាក្វាន់ នេះអែង។ ខ្ញុំសុំចំលងអត្ថបទនេះទាំងស្រុង ដែលមានចំនួន៦៣ទំព័រ គេក៏ព្រមថតចំលងអត្ថបទនេះអោយខ្ញុំ បានជាហ្វីលមួយខ្សែវែង។ លុះមកដល់ស្រុកវិញ ខ្ញុំផ្តិតចេញជាសន្លឹកអក្សរ ហើយអនិច្ចា! នៅតែអង្គុយមើលៗ វាយសេចក្តីមិនបែកសោះ។ ខ្ញុំបានយកអក្សរថតផ្តិតនេះ បិទធ្វើជាសៀវភៅមួយ ហើយយកទៅតំកល់ទុកនៅសមាគមអ្នកនិពន្ធខ្មែរ ព្រោះសង្ឃឹមក្រែងថ្ងៃក្រោយ មានលោកណាមួយក្នុងបន្តាអ្នកនិពន្ធអ្នកស្រាវជ្រាវ អាចធ្វើការបកប្រែអត្ថបទនេះបាន។ ស្រាប់តែពីរឆ្នាំក្រោយមក បាត់សៀវភៅនោះជាអាសារបង់ទៅ សួររកដើមចុងមិនឃើញ ខ្ញុំនឹកថា : អ្នកដែលឆ្លៀតបំបាត់សៀវភៅនេះ ពិតជាមានបំនងយកទៅធ្វើអែកសារផ្ទាល់ រឺ មួយលាក់កំបាំងកុំអោយយើងធ្វើការបកប្រែបាន។ តែសំនាងល្អខ្ញុំនៅសល់ហ្វីល ក៏ផ្តិតបានមួយច្បាប់ទៀត ហើយក៏ចាត់ចែងបកប្រែបោះពុម្ពអោយបាន

ទោះ មិនទាន់ហ្មតចត់ ក៏បានជាផ្លូវសំរាប់អ្នកសិក្សា អ្នកស្រាវជ្រាវមួយផ្នែកធំដែរ។ មួយទៀតសំរាប់អ្នកសិក្សាបានជា
ប្រភពមួយទៀតប្រៀបធៀបនឹងប្រភពដទៃៗផង ។ ការបកប្រែនេះបានធ្វើទុក្ខខ្ញុំយ៉ាងខ្លាំង ព្រោះខ្ញុំត្រូវការពឹងរកអ្នក
ចេះអក្សរចិន ហើយរបៀបចិនបុរាណទៀត អែអ្នកចេះចិនសម័យថ្មី អានមិនយល់ច្បាស់វាយសេចក្តីពុំបានន័យឡើយ។
មិត្តខ្ញុំម្នាក់ឈ្មោះ អ៊ឹង ឡាយ ជាអ្នកនិពន្ធប្រលោមលោកច្រើនរឿងដែរ តាំងពីឆ្នាំ ១៩៥៥ - ៥៦ ហើយតមកគាត់ជាអ្នក
អែកទេសប្រែរឿងភាពយន្តចិន ទោះជារឿងបុរាណដែលប្រើពាក្យជំនាន់ចាស់ៗ ក៏គាត់ធ្លាប់ជួបប្រទះគ្មានសល់។ មិត្ត
អ៊ឹង ឡាយបានធនាជួយខ្ញុំពេញកំលាំង។ លោកប្រែអត្ថបទនេះមួយចប់អោយខ្ញុំ ហើយត្រង់ពាក្យណាពិបាកពេកគាត់ដេ
ញសួរទៅវចនានុក្រមចិន ហើយកត់ទាំងពាក្យពន្យល់ទុកអោយខ្ញុំផង។ មានមិត្តខ្ញុំម្នាក់ទៀតឈ្មោះ ម៉ា អៀត ធ្លាប់ធ្វើ
ជាគ្រូបង្រៀនអក្សរខ្មែរនៅសាលាចិន ក៏បានជួយបកប្រែខ្ញុំមួយចំនែកផ្សេងទៀតដោយអន្លើខ្លះ មិនបានចប់ចុងចប់ដើ
មទេ។ ខ្ញុំយកសំណៅបកប្រែទាំងពីរនេះមកមើល សំរួលកែកុនផ្សំបញ្ចូលគ្នា ដោយផ្ទៀងផ្ទាត់ខ្លះជាមួយអក្សរចិនជាអត្ថ
បទដើម ដែលខ្ញុំមើលបានដោយអន្លើៗ ផ្សេផ្សំផង ហើយខ្ញុំផ្ទៀងជាមួយនឹងស្នាដៃប្រែរបស់លោក ប៉េលិយោត ជាភា
សាបារាំងទៀត។ ប៉ុន្តែនៅតែមិនអស់ចិត្ត។ លុះថ្ងៃមួយ ខ្ញុំជួបគ្រូចាស់ខ្ញុំ ដែលអិលូវអោយុ៧១ ឆ្នាំហើយ ឈ្មោះលោក
តាំង ស៊ុយគង់។ កាលខ្ញុំរៀនអក្សរចិន (១៩៤០) លោកជាសាស្រ្តាចារ្យខាងអក្សរសាស្រ្ត ធ្លាប់ចេះចាំរឿងព្រេងសព្វគ្រប់
ជាអ្នកសិក្សាដោយខ្លួនអែង តាមរបៀបចិនបុរាណ។ អិលូវលោករស់នៅជាមួយកូនចៅ ដែលសុទ្ធសឹងជាមន្ត្រីរាជការ
យើងខ្លះ និងខ្លះជាអ្នកជំនួញ។ ខ្ញុំស្នើសុំអោយគាត់ជួយផ្ទៀងជាមួយខ្ញុំ។ លោកតាទទួលដោយរីករាយ ពេញចិត្តនឹងកិច្ច
ការនេះ ដូចមិត្តខ្ញុំទាំងពីរខាងលើដែរ។ គាត់ពន្យល់ ខ្ញុំម្តងមួយវគ្គៗ ខ្ញុំផ្ទៀងមើល តើត្រូវន័យសព្វគ្រប់ដូចសេចក្តីប្រែរប
ស់ខ្ញុំរឺទេ? បើខ្វះខ្លះខ្ញុំ ក៏បន្ថែម បើមិនងាយយល់ ខ្ញុំក៏ធ្វើន័យលក្ខណៈ ព្យល់ខាងក្រោមតាមគាត់ប្រាប់។ អស់រយៈបីខែ
ទៀត ទើបបានសំរេចយកសេចក្តីបាន ហើយដែលចាត់ការបោះពុម្ពពេលនេះ។

ម្យ៉ាងទៀត អំពីសំនៀងភាសាចិន មានច្រើនយ៉ាងតាមគ្រាមភាសា (Dialeeles) ដូចជាភាសាប៉េកាំង ស៊ាងហៃ កន្តាំង ទា
ជីវ ហុកគៀន។ល។ ខ្ញុំសូមបញ្ជាក់ថា លោកជីវតាក្វាន់ មានដើមកំនើតនៅវេ៉ងតា ខែត្រ ជាក់កាង ក្នុងភូមិភាគចិនខាង
ត្បូង។ ដូច្នេះសំដីភាសាលោកក៏ពិសេសតាមស្រុកនោះដែរ។ តែមកដល់ប្រទេសចេនលាគ្មានចិនស្រុកគាត់មកនៅទេ
មានតែចិនខែត្រ គង់ទុង រឺ ក្វាងតាំង ខ្មែរយើងធ្លាប់ហៅ ចិនកន្តាំង ចិនទាជីវ នេះអែង មករស់នៅ។ ម្លោះហើយសំលេង
ពាក្យដែលគាត់ប្រែពីខ្មែរទៅពិបាកស្តាប់ណាស់ ព្រោះតាមសំនៀងពួកកន្តាំង និង ទាជីវជាអ្នកប្រែអោយគាត់ផង និងតាម
សំនៀងភាសាផ្ទាល់របស់ស្រុកកំនើតគាត់ផង។ ក្នុងការបកប្រែនេះ យើងខ្ញុំសំរេចគ្នាថា យកតាមសំនៀងចិនទាជីវជាគោ
ល ព្រោះមានតែចិនទាជីវទេ ដែលរស់នៅភាគច្រើនលើសលុបគេក្នុងស្រុកខ្មែរ ហើយអ្នកចេះភាសាចិន រឺ ក៏ពាក្យខ្មែរ

ខ្លះ ដែលក្លាយមកពីចិនសុទ្ធតែអានតាមសំនៀងចិនទាជីវទាំងអស់។

ដូច្នេះខ្ញុំ សូមអភ័យទោសជាមុន ពីសំនាក់លោកអ្នកដែលចេះចិនជ្រៅជ្រះ ក្រែងលោកខ្ញុំ និងគីគ្នាខ្ញុំ ផ្សំគ្នាប្រែនេះមិនទាន់សព្វគ្រប់ខ្ទះចន្លោះពាក្យពេចន៍។

ភ្នំពេញ ខែមិថុនា គ.ស. ១៩៧១

លី ធាមតេង

# ១ - ប្រពៃណីអ្នកស្រុកចេនលា

## សេចក្តីផ្តើម

រឿងរ៉ាវទាំងនេះ លោកជីវ តាក់គង់(១) បាននិពន្ធឡើងក្នុងសម័យសន្តិវង្ស ងន់(២) គឺនៅស្រុក វេងតា(៣)ហើយក្រោយមកលោកហ្វូវគង់ បានកែសំរួលក្នុងរវាង រាជសន្តិវង្ស ម៉េង(៤)ក្នុងស្រុកសេងអាន(៥)

១ = នេះតាមសំលេងចិនទាជីវ បើអានតាមសំលែងចិនប៉េកាំង : ចូវតាក្វាន់ តែយើងធ្លាប់មកថា ជីវតាក្វាន់ៗ។

២ = សន្តិវង្សងន់នេះ មានស្តេចច្រើនអង្គ តែនេះក្នុង គ.ស ១២៩៥ គឺត្រូវលើស្តេចឈ្មោះ ងន់ សេងចុង នាមសំរាប់រាជវង្ស ងន់ចេង។ ៣ = ស្រុកវេងតា នៅក្នុងខេត្តជាក់កាង (ចិនខាងត្បូង)។ ៤ = សន្តិវង្សម៉េង ចូលមកក្នុងសតវត្សទី ១៣ -១៤ នៃគ.ស។ ៥ = នៅក្នុងខេត្តហោណាំ (ហូណាន់)។

## សេចក្តីអធិប្បាយទាំងស្រុងមានដូចតទៅះ

ចេនឡា រឺ ចាមឡា អ្នកប្រទេសហៅខ្លួនអែងថា «កាន់ផៃចឺ» តាមកំនត់ខ្លះរបស់ពួកបសឹ្ចមប្រទេស បានហៅថាកាំពូចឺ ដែលមានសំលេងស្រដៀងនឹង «កាំពូចេ» ដែរ។

ខ្ញុំចាប់ធ្វើដំនើរចេញពីស្រុក «អ៊ូជីវ» ទៅដល់សមុទ្រ «ការជីវ» ក៏បានទៅដល់ទីក្រុងចាម្ប បន្តដំនើរបន្តោយខ្យល់ចេញពីក្រុងចាម្ប ទៅអស់រយ:ពេលកន្លះខែទៀត ក៏បានទៅដល់ស្រុក ចេញផូវ (ជម្ពូ?) ដែលជាព្រំដែននៃប្រទេសនេះ។ លុះចេញពីចេងផូវទៅទៀត ឆ្លងសមុទ្រ យុនលុន ក៏ទៅដល់មាត់ពាម គឺបែកចេញពីមាត់សមុទ្រទៅជាដៃទន្លេច្រើនច្រកណាស់។ក្នុងបន្ទាច្រកទាំងនោះ មានតែច្រកទី៤ទេ ទើបអាចចូលទៅបាន ក្រៅពីនេះគេដឹងថា មានទឹករាក់ណាស់ នាវាធំៗមិនអាចធ្វើដំនើរបានឡើយ ត្រង់ពាមមានច្រកនោះ ឃើញមានព្រៃទ្រុប ហើយក្រៅពីនេះមានវាលខ្សាច់ពណ៌លឿង និងមានដើមបបូសនិងអំពៅព្រៃ ដុះបែកផ្កាសសំព្រូស ម្ល៉ោះហើយ អ្នកដំនើរពិបាកចំនាំច្រកចូលទៅណាស់។

ចូលផុតពីមាត់ពាម ធ្វើដំនើរប្រមាណកន្លះខែទៀត ទើបបានទៅដល់ស្រុកមួយឈ្មោះ ឆេនាំ (ឆ្នាំង?) ដែលជាខេត្តមួយនៃប្រទេសនេះ។ លុះធ្វើដំនើរពី ឆេនាំ បន្តោយតាមទឹកហូរទៅជើង អស់ពេល ១០ថ្ងៃទៀត កាត់ភូមិ ពូលូវឈឹង (ប្រែថាភូមិកន្តាលផ្លូវ) ហ៊ុតឈឹង (ភូមិព្រះពុទ្ធ)(១) ឆ្លងកាត់សមុទ្រទឹកសាប(២) ទៅទៀត ទើបបានដល់ទីក្រុង កាងពាងឈូ (កំពែងជូរ?)។ ក្នុងនេះ មានទំហំ ៥០ លី (១លីប្រវែង ១.៨០០ហត្ថ) បើតាមសៀភៅពួកបសឹ្ចមប្រទេសសរសេរថា ប្រទេសនេះ មានទំហំដី៧.០០០លី និងមានព្រំប្រទល់ ខាងជើងទល់នឹងក្រុងចំប៉ា គឺត្រូវ

ធ្វើដំនើរ អស់ពេលកន្លះខែ ខាងនិរតីនៅឃ្លាតពីស្រុកសៀមចំងាយផ្លូវកន្លះខែដែរ នៅខាងត្បូងឃ្លាតពីទីក្រុង «ហ្វូងអ៊ុ» ចំងាយផ្លូវ១០ថ្ងៃ អែខាងកើតប្រទេសនេះគឺមហាសមុទ្រ ហើយដែលប្រទេសមួយធ្លាប់ទាក់ទង ខាងសេដ្ឋកិច្ចជាមួយ ស្រុកយើងតាំងពីដើមរៀងមកផង។

១ = លោក ប៉េលីយោត Pelliot សង្ស័យថា ពោធិសាត់ តែពិតគឺ ភូមិព្រៃភព ព្រោះជាពាក្យសំគាល់នាមព្រះពុទ្ធដែរ។ ២ = ពាក្យ ទលេបាលី ប្រែថាសមុទ្ទ សព្វថ្ងៃក្លាយជា ទន្លេសាបវិញ។

នៅគ្រាដែលប្រទេសចិន (ក្នុងរាជ្យសន្តិវង្សម៉ុងហ្គោល) បានត្រួត្រាលើមហាសមុទ្រក្នុងទ្វីបលោកហើយ លោកថមពល (មេទ័ពធំ) ឈ្មោះ ចុន តូវ ដែលនៅឈរប្រចាំការត្រួតត្រាទីក្រុងចាមបានចាត់ មន្ត្រីពីរនាក់គឺ លោក ហ៊ូប៉េក ហូវ អ្នកមានប៉ានមាស១ និងលោក ឆាយ ហូវ អោយទៅកាន់ប្រទេសចេនលា តែត្រូវប្រទេសនេះចាប់ឃុំទុកមិនអោយមកវិញ។ លុះមកដល់រជ្ជកាលស្តេច ងន់ ចេង (គ.ស.១២៩២) ខែទី៦ ព្រះរាជាអង្គនេះ ទ្រង់ចាត់បេសកម្មទូតមួយមកប្រទេសចេនលា ហើយពេលនោះ ខ្លួនខ្ញុំក៏ត្រូវចាត់មកជាមួយដែរ។ គឺនៅក្នុងខែទី ២នៃឆ្នាំបន្ទាប់មក យើងបានចាកចេញពីស្រុក ម៉េងជីវ នោះមកទៀត។ លុះថ្ងៃ១៥ ខែទី៣ ទើបដល់ទីក្រុងចាម នៅកន្លាលផ្លូវជួបនឹងខ្យល់បក់បញ្ច្រាសពីមុខមកវិញ ដែលជាហេតុនាំអោយមានការ រអាក់រអួលក្នុងដំនើរ។ ដល់មកខែ ៧ដែលជាសរទរដូវ ទើបបានមកដល់ប្រទេសនេះ ព្រមចំនុចចុះចូលទៅ(១)។

១ = ត្រង់នេះ តាមសេចក្តីប្រែលោក ប៉េលីយោត មិនលឺថា ព្រមចំនុចចូលទេ តែនេះប្រែតាមប្រយោគចិន អក្សរដូច្នេះន័យនេះបានត្រឹមតែថាគេព្រមរាក់ទាក់ទទួលបេសកជនប៉ុណ្ណោះ។

លុះដល់មករជ្ជកាលស្តេច តាយ តេក (គ.ស. ១២៩៧) ខែទី៦ ខ្ញុំជិះនាវាត្រលប់មកវិញ ហើយដល់ថ្ងៃ ១២ ខែ ៨ ទើបនាវាចូលចត ដល់កំពង់ផែស្រុកស៊ីម៉េង។

ចំពោះរឿងប្រពៃណី និង កិច្ចការនៃប្រទេសចេនលានេះ ខ្ញុំមិនបានដឹងល្អិតល្អន់អស់សេចក្តីសព្វគ្រប់មែន តែខ្ញុំបានដឹងដោយត្រួសៗអាចនឹងជំរាបបានដែរ។

## ១. បរិវេណនៃក្រុង

បរិវេណនៃក្រុងនេះ មានទំហំ ២០លី មានទ្វារ ៥។ ទ្វារទាំងនោះសុទ្ធតែសាងកំរាស់ជាពីរជាន់ក្នុងក្រៅ គឺនៅទិសខាងកើតមានទ្វារពីរ។ ក្រៅពីនេះ ក្នុងមួយទិស មានទ្វារតែមួយទេ។ នៅក្រៅកំពែងក្រុង សុទ្ធតែមានប្រលាយទឹកធំៗ ពីក្រៅប្រលាយនោះមានផ្លូវដើរទៅកាន់ស្ពានធំៗ ហើយនៅសងខាងស្ពាននិមួយៗមានទេវរូបថ្ម ៥៤

ដូចជាមេទ័ពថ្មដ៏ធំៗដូច្នេះដែរ។ រូបទាំងនោះដូចៗគ្នានៅតាមច្រកទាំងប្រាំ។ បង្កាន់ដៃស្ពានទាំងនេះគេធ្វើអំពីថ្ម ហើយមានឆ្លាក់រូប ពស់ដ៏ធំ(១) ដែលមានក្បាល៩ អែរូបថ្មទាំង ៥៤នោះ សុទ្ធតែយកដៃចាប់ទាញពស់នេះអែង ហាក់ដូចជាមិនចង់អោយស្ទុះទៅរួច។ នៅខាង លើខ្លោងទ្វារ មានពុទ្ធរូបថ្មប្រាំអង្គបែរភ័ក្ត្រទៅទិសខាងលិច ហើយមួយអង្គដែលស្ថិតនៅចំកន្តាលគេមានទឹកមាសល្អស្រស់ផង។ នៅសងខាងទ្វារ មានឆ្លាក់រូបដំរីថ្មទៀត។

១ = ពស់នេះ បើតាមខ្មែរគឺជានាគ។ ជីវតាក្វាន់ធ្លាប់ស្គាល់នាគចិន មានរូបផ្សេងបានជាហៅនាគខ្មែរថាពស់

កំពែងទីក្រុង គេធ្វើពីថ្មទាំងអស់ មានកំពស់ ២០ ហត្ថតំរៀបថ្មយ៉ាងជិត ហើយមាំណាស់។ នៅពីលើគ្មានស្មៅដុះឡើយ តែនៅ ចន្លោះមួយជុំៗមានដាំដើមជ្រៃ។ អែផ្ទៃក្នុងនៃកំពែងដែលមានចន្លោះពីគ្នាដល់ទៅ ១០០ហត្ថនោះ ស្ថិតនៅជាដីជំរាល បីដូចជាជំរាលនៃភ្នំ រលីងស្អាតណាស់។ លើកំពែងដែលមានផ្ទៃជាជំរាលនោះ មានទ្វារធំៗ ដែលបិទជិតនៅពេលយប់ ហើយបើកចំហរនៅពេលថ្ងៃតាំងពីព្រលឹម និងមានអ្នកយាមប្រចាំការជានិច្ច។ សត្វឆ្កែគេមិនអោយចូលក្នុងទ្វារនេះទេ។ ជនណាដែលធ្លាប់មានទោសត្រូវគេកាត់ម្រាមជើង ក៏មិនអោយចូលដែរ។ កំពែងព័ទ្ធជុំវិញនោះមានជ្រុងជ្រោយល្អណាស់ ហើយនៅជ្រុងនិមួយៗសឹងមានប្រាង្គថ្មមួយខ្ពស់នៅប្រចាំគ្រប់ជ្រុង។

នៅកន្តាលទីក្រុងនេះ មានប្រសាទមាសមួយ(ក) និងនៅជិតខាងនេះមានប្រាង្គប្រាសាទជាង២០ទៀត ព្រមទាំងមានបន្ទប់ថ្មចំនួនច្រើនបន្ទប់ផង ។ នៅប៉ែងខាងកើតមានស្ពានមាសមួយមានរូបតោមាស២ ស្ថិតនៅអមខាងឆ្វេង និងខាងស្តាំស្ពានមាស។ មានព្រះពុទ្ធរូបមាស ៨អង្គ តំកល់នៅតំរៀបគ្នាចំពីក្រោមប្រាង្គសិលា។ នៅខាងជើងប្រាសាទមាសចំងាយប្រមាណជាងមួយលី មានប្រាសាទស្ពាន់មួយទៀតដែលមានកំពស់ខ្ពស់ជាងប្រាសាទមាស គួរអោយគយគន់ណាស់។ ចំពីក្រោមប្រាសាទស្ពាន់នោះ ឃើញមានបន្ទប់ថ្មប្រហែលជាដប់ដែរ។ ចេញពីនេះទៅខាងជើងថែមមួយលីទៀត គឺជាព្រះរាជដំនាក់ដែលស្តេចគង់នៅ។ នៅក្នុងល្វែងដែលជាព្រះដំនាក់នោះ មានប្រាង្គមាសមួយទៀត។ ទំនងជាដោយហេតុនេះហើយ ដែលពួកឈ្មួញបរទេសតែងជំនាលថា ប្រទេសចេនលាថ្កុំថ្កើងរុងរឿងណាស់។

ក = លោកប៉េលីយោត យល់ថាប្រាសាទនេះ គឺប្រាសាទបាយ័ន។

ចេញពីកំពែងតាមទ្វារខាងត្បូងទៅ ចំងាយប្រមាណជាជាងកន្លះលី តាមពាក្យចចាមអារាមគេនិយាយថាចេតិយលូប៉ិន(១) សង់តែមួយយប់។ ផ្នូរសព រឺ ចេតីយ លូប៉ិន ស្ថិតនៅក្រៅកំពែងខាងត្បូងជាងកន្លះលី ហើយមានបរិវេណ

ព័ទ្ធជុំវិញប្រមាណជាងដប់លី និងមានបន្ទប់ថ្មច្រើនរយទៀតផង។ នៅស្រះខាងកើតកំពែងនគរប្រមាណ១០លី មានប្រាសាទថ្មីមួយទៀត(២) មានបរិវេណព័ទ្ធជុំវិញប្រវែង ១០០លី។ នៅក្នុងប្រាសាទនេះ មានព្រះពុទ្ធរូបមួយអង្គទ្រង់ផ្ទុំធ្វើពីស្ពាន់ ហើយមានទឹកចេញជានិច្ចពីផ្ចិត ហូរធ្លាក់ចុះទៅក្នុងស្រះធំមួយ នៅពីខាងជើងប្រាសាទនេះ។ នៅទិសខាងជើងកំពែងនគរចំងាយប្រមាណ ៥លី មានប្រសាទមាសរាងបួនជ្រុង(៣) និងមាន បន្ទប់ថ្មជាច្រើនរយ ហើយនៅក្នុងនោះគេឃើញមានព្រះពុទ្ធរូបមាស រូបសិង្ហមាស រូបដំរី រូបគោ រូបសេះ និងវត្ថុដទៃទៀតធ្វើពីស្ពាន់ ច្រើនអិតគណនា។

១ = តាមសេចក្តីប្រែរបស់លោក ប៉េលីយោត ថា Lou-Pan ហើយលោកចុះសេចក្តីយល់ថាជាប្រសាទអង្គរវត្ត។ តាមចិនលូប៉ិន ជាឈ្មោះមេជាងរចនាក្នុងរឿងព្រេង ដូចខ្មែរយើងនិយាយពីពិសនុការអ្នកសាងប្រាសាទដែរ)។

២ = លោក ប៉េលីយោត យល់ថា ជាប្រាសាទមេបុណ្យខាងលិចដែលគាត់បន្ថែមថា ប្រហែលជាគេច្រលំ ជាទិសខាងកើតទៅវិញ។ ៣ =ទំនងជាប្រាសាទនាគព័ន្ធ។

## ២. ដំនាក់លំនៅស្ថាន

ព្រះដំនាក់ ផ្ទះនាម៉ឺនមន្ត្រី និងផ្ទះអ្នកមានទាំងអស់សុទ្ធតែបែរមុខទៅកើត។ ព្រះរាជដំនាក់ ស្ថិតនៅខាងជើងប្រាសាទមាស និងស្ពានមាស ហើយនៅជិតមាត់ទ្វារក៏មានបន្ទាយព័ទ្ធជុំវិញប្រវែង ៥ រឺ ៦លី។ ក្បឿងប្រក់តួប្រាសាទកន្តាលធ្វើពីសំនរ អែអគារផ្សេងទៀត សឹងប្រក់ក្បឿងធ្វើពីដីដុតពណ៌លឿង។ សសរនិងស៊ុមទ្វារសុទ្ធតែឆ្លាក់ រឺគូររូបរចនាផ្សេងៗ តែភាគច្រើនគឺរូបព្រះពុទ្ធ។ ដំបូលទាំងនោះល្អមើលណាស់។ របៀងប្រាសាទ និង ថែវយ៉ាងវែងអាចដើរបាន ជាផ្លូវខ្វាត់ខ្វែង ហើយដំបូលនោះក៏ខ្ពស់ៗសំបើមណាស់។ ទីនេះជាកន្លែងព្រះរាជវាំងដែលស្តេចទ្រង់ប្រកបកិច្ចការផែនដី មានបង្អួចមាសមួយនៅខាងស្តាំ និង ខាងឆ្វេងនៃកន្លែងស្តេចគង់ប្រថាប់ មានសសរបួនជ្រុងតំកល់កញ្ចក់តំរៀបគ្នាប្រមាណជា៤០ រឺ ៥០ បន្ទះ ដាក់ដង្ហែតាមជ្រុងបង្អួចនេះ កំនល់ទ្រមានរូបរាងជាដំរី (ត្រង់នេះគឺជាបុស្បុកមួយ ដែលមានសសរបួន និងក្បាច់លំអរដោយកញ្ចក់ជើងទ្រធ្វើពីរូបដំរី តែលោកជីតាក្វាន់ សរសេរថា ជាស៊ុមមួយ ព្រោះឃើញមានតែគ្របជុំវិញ)។

ខ្ញុំលឺគេនិយាយថា ទីត្រង់នេះ មានរបស់ប្លែកៗច្រើនណាស់ ប៉ុន្តែបំរាមតឹងតែងពេក មិនអាចអនុញ្ញាតអោយចូលមើលបាន។ ក្នុងបន្ទារឿងប្លែកទាំងនោះ មានការណ៍មួយថា នៅកន្តាលប្រសាទមានប្រាង្គមាសមួយ ហើយថារាល់យប់ ស្តេចតែងឡើងទៅផ្ទុំលើប្រាង្គមាសនោះ។ អ្នកស្រុកគេមានជំនឿហើយនាំគ្នានិយាយថា នៅក្នុងប្រា

សាទមាសនោះអែង មានបិសាចមួយ មានរូបពស់ក្បាលប្រាំបួន(២)។ បិសាចនោះជាព្រះភូមិរក្សាព្រះនគរ។រាល់យប់ បិសាចតែងជំនែងខ្លួនជាមនុស្សស្រី ហើយស្តេចត្រូវរួមផ្តេកផ្តិតនឹងនាងនេះ សូម្បីតែមហេសី រី ស្នំស្និទ្ធព្រះអង្គ ក៏មិនហ៊ានចូលទៅក្នុងទីនោះដែរ។ លុះដល់មជ្ឈឹមយាម ទើបស្តេចចេញមកពីនាងពស់នោះ មករួមរ័ក្សនឹងមហេសី រី ស្រីស្នំដទៃទៀតបាន។ បើបាត់ពស់នោះមិន និម្មិតមកទេ នោះថាគ្រោះថ្នាក់នឹងមកដល់អាយុស្តេចហើយ រឿងរ៉ាវអាក្រក់នឹងកើតឡើង។ បើស្តេចមិនបានយាងចូលទៅទីនោះមួយយប់ណា ហើយពេលនោះអពមង្គល នឹងពិតជាកើតឡើងភ្លាមមិនខានដែរ។

២ = ពស់ក្បាលប្រាំបួននេះគឺជានាគ ព្រោះនាគខ្មែរមានខ្លួនជាពស់ អែនាគចិនមានជើងក្បាលតូចអិតពពារទេ។

បន្ទាប់មក ជំនាក់ញាតិវង្ស រីលំនៅនាម៉ឺន មន្ត្រីធំៗ សង់យ៉ាងធំទូលាយស្កុកស្គម្ភប្លែកពីផ្ទះអ្នកស្រុកសាមញ្ញ។ ផ្ទះទាំងនោះសុទ្ធតែប្រក់ស្លឹក មានតែផ្ទះអ្នកធំ និង វិហារទេដែលប្រក់ក្បឿង។ ហើយទំហំផ្ទះទាំងនោះត្រូវសង់ទៅតាមលំដាប់យសសក្តិនៃម្ចាស់ផ្ទះផង។ ចំនែកផ្ទះប្រជារាស្ត្រវិញ សុទ្ធតែប្រក់ស្លឹក រី ស្បូវ គេមិនហ៊ានប្រក់ក្បឿងទេ អែទំហំសោត សង់ទៅតាមធនធានខ្លួន តែមិនហ៊ានសង់អោយដូចលំនាំអ្នកធំឡើយ។

### ៣. សំលៀកបំពាក់ និង គ្រឿងអលង្ការ

អ្នកស្រុកទាំងអស់ ចាប់តាំងពីស្តេចចុះទៅ ទាំងស្រីទាំងប្រុស សុទ្ធតែបួងសក់ទាំងអស់ ហើយគេតែងលែងខ្លួនទទេស្អាត មានតែសំពត់មួយផ្ទាំងតូចវ័ណ្ឌជុំវិញខ្លួន របៀបគេចង់ពុង ហើយបើត្រូវការចេញទៅណាមកណា គេយកកំនាត់មួយផ្ទាំងទៀតធំជាងមុន មករុំស្រោបថែមពីលើ។ ការស្លៀកពាក់នេះ មានលក្ខខ័ណ្ឌទៅតាមឋានៈទៀត។ ព្រះសស្ត្ររបស់ស្តេច មានតំលៃជាមាសបីបួនតំលឹងគឺល្អដាច់ពីសំលៀកបំពាក់អ្នកផងទាំងពួង។ អ្នកស្រុកនេះចេះត្បាញសំពត់ប្រើហើយ តែមានប្រើសំពត់មកពីស្រុកសៀម និង ចាមផងដែរ។ សំពត់ពិសេសមកពីបស្ចឹមប្រទេសដែលមានសាច់ម៉ដ្ឋល្អ មានតែស្តេចទេដែលមានប្រើ គឺសំពត់ផ្កាសរសៃសូត្រឆ្មារ ស្តេចពាក់មកុដមាស បើជួលកាលមិនពាក់មកុដទេ គឺពាក់កំរងផ្កាដូចជាផ្កាម្លិះជាដើម ព័ទ្ធជុំវិញព្រះសិរ។ នៅលើកំពូលព្រះកេស មានស្បៀតសក់ដាំត្បូងពេជ្រយ៉ាងធំទៀតផង។ គ្រាន់តែគ្រឿងអលង្ការដែលពាក់នៅនឹងព្រះបាទ និងព្រះហស្តមានទំងន់ដល់ទៅបីនាឡិ។ នៅគ្រប់តែម្រាមមានពាក់ចញ្ចៀនដែលមានដាំពេជ្រភ្នែកឆ្មា។ បាតព្រះហស្ត និង បាតព្រះបាទមានលាបពណ៌ក្រហម ហើយនៅពេលដែលទ្រង់យាងចេញមកម្តងៗ តែងកាន់ព្រះខាន់មាសមួយជានិច្ច។

ចំនែកប្រជារាស្ត្រវិញ មានតែស្ត្រីភេទទេ ដែលអាចលាបថ្នាំក្រហមនៅបាតដៃបាតជើងបាន អែប្រុសៗមិនហ៊ាន

លាបទេ។ ព្រះញាតិវង្ស និងមន្ត្រីធំអាចប្រើកំនាត់ផ្ការង្វើលៗបាន តែមន្ត្រីធម្មតាប្រើបានតែត្រឹមផ្កាចុងជាយប៉ុណ្ណោះ ចំនែកពាស្ត្រសាមញ្ញ បើស្រីៗ អាចប្រើសំពត់ផ្កាបានខ្លះដែរ។

ជនជាតិចិនដែលទើបមកដល់ប្រទេសនេះថ្មីៗ ទោះបីប្រើសំពត់មានផ្កានៅជាយទាំងសងខាង ក៏គេមិនថាអីដែរ ព្រោះគេសន្មតថា ជាពួកមិនទាន់ដឹងទំនៀមស្រុក ហៅថា ពួក ង៉ានទឹង ប៉ា ឆា (មិនដឹងភាសា?)។

## ៤. អំពីមន្ត្រី

ប្រទេសនេះមានរដ្ឋមន្ត្រី មេទ័ព និងហោរា ហើយមន្ត្រីក្រោមពីនោះ មានច្រើនឋានៈទៀត ដូចជានៅប្រទេសចិនដែរ ប្លែកគ្នាតែឈ្មោះហៅ។ មន្ត្រីទាំងនេះភាគច្រើនជាពូជពង្សរបស់ស្តេច បើមានអ្នកក្រៅចូលធ្វើជាមន្ត្រីផងទាល់តែអ្នកនោះយកកូនទៅថ្វាយអោយធ្វើជាស្នំស្តេច។ ការធ្វើដំនើរនៃមន្ត្រីទាំងនោះ គេសំគាល់តាមគ្រឿងហែហមតាមឋានៈ។ អ្នកធំជាងគេអង្គុយលើគ្រែស្នែងមាស មានបាំងក្លស់ដងមាសបួន។ អ្នកបន្ទាប់មកទៀត គ្រែស្នែងមាសក្លស់ដងមាសពីរ ចុះមកទៀតគ្រែស្នែងប្រាក់ មានក្លស់ដងមាសមួយ។ អ្នកតូចបន្តមកចេះតែថយក្លស់ដងមាសតែមួយ រួចក្លស់ប្រាក់មួយអិតមានគ្រែស្នែង។

ចំពោះមន្ត្រីដែលត្រូវជិះគ្រែស្នែងប្រាក់ និងក្លស់ដងមាសមួយឡើងទៅ សុទ្ធតែហៅ ប៉ាតេង (ម្រតេង) រឺ អាំតេង (អំដែង?)។ អ្នកដែលមានក្លស់ដងប្រាក់ ហៅថា សីលាត់ទី (ស្រីស្និន?)។ ក្លស់នោះ គេយកសំពត់ជាតិសូត្រដែលធ្វើមកពីប្រទេសចិនពាស ហើយទំលាក់ចុងរំភាយចុះសឹងដល់ដី។ អែឆ័ត្រតាំងយូរ គេយកសំពត់សូត្រពណ៌ខៀវមកពាស ហើយទំលាក់រំភាយខ្លីបបន្តិចដែរ រួចយកប្រេងមកលាបយ៉ាងរលើបទៀតផង។

## ៥. អំពីលទ្ធិសាសនាបីបែប

អ្នកចេះដឹង (ពួកព្រាហ្មណ៍?) គេហៅថា ប៉ាយាប(១) លោកសង្ឃ គេហៅថា ជូគូ(២) ពួកតាបសគេហៅថា ប៉ាស៊ីវី(៣)។

១ =តាមសេចក្តីប្រែរបស់លោក ប៉េលីយោតថា ប៉ាយី ពាក្យនេះទំនងជាមកពីពាក្យ បណ្ឌិត។ ២ លោកសង្ឃខាងពុទ្ធសាសនា ប្រហែលមកពីពាក្យព្រះគ្រូ។ ៣ = លោក ប៉េលីយោត ប្រែថា ប៉ាសិវៃ ប្រហែលមកពីពាក្យ បស្វ:

ដែលហៅថា ប៉ាយាប នេះ មិនដឹងជារៀនពីកន្លែងណាទេ ខ្ញុំមិនដែលឃើញសាលា រឺ ទីកន្លែងរៀនសោះ ខ្ញុំឃើ

ញតែរូបពួកគេនេះអែង ដែលស្លៀកពាក់ដូចជាធម្មតាដែរ ប៉ុន្តែមានប្លែកត្រង់មានពាក់អំបោះស វេញមួយខ្សែ នៅក ហើយអំបោះនេះ ពាក់ជាប់នឹងក អស់មួយជីវិត។ គេតែងរើសយកពួក ប៉ាឃាប នេះអែងធ្វើជាមន្ត្រី ព្រោះគេទុកជអ្នកចេះដឹងជាន់ខ្ពស់ហើយ។

ចំនែកលោកសង្ឃវិញ កោរព្រះកេស គ្រងចីវរពណ៌លឿងបញ្ចេញស្មាខាងស្តាំ ហើយនិមន្តដោយជើងទទេ អិត ពាក់ស្បែកជើងឡើយ។ ព្រះវិហារមួយ គេអនុញ្ញាតអោយប្រក់ក្បឿងបាន ហើយនៅកន្តាលព្រះវិហារនោះមា នតំកល់ព្រះពុទ្ធរូបមួយព្រះអង្គ ដែលមានភិនភាគ ដូចព្រះសក្យមុនីដែរ(៤) គេហៅថា ពុតលៃ លាបលន ពណ៌ ក្រហម ដោយគេយកដីសមកសូនធ្វើហើយលាបពណ៌ផ្សេងៗ គ្មានភិនភាគអ្វីក្រៅពីនេះទេ ច្រើនតែកសាងអំពី ស្តាន់ ហើយគ្មានជួងសួរ រគាំង ទង់អ្វីទាំងអស់។ ព្រះសង្ឃឆាន់ត្រីសាច់បាន តែមិនឆាន់ស្រាទេ ហើយគេអាច រៀបម្ហូបត្រីសាច់ទាំងនេះថ្វាយព្រះផង។ ក្នុងមួយថ្ងៃលោកនិមន្តទៅបិណ្ឌបាតពីផ្ទះអុបាសកតែមួយដងទេ ហើយ គ្មានរៀបជន្តាំស្លនៅក្នុងវត្តឡើយ។ លោកឆាន់មួយដងក្នុងមួយថ្ងៃ។
៤ = តាមមហាយាន គេជឿថា មានព្រះពុទ្ធពីរអង្គ គឺព្រះពុទ្ធដើមនៅឋានសួគ៌គឺនាម អាមិតាភៈ និងព្រះពុទ្ធដែល ត្រាស់ដឹងនៅស្ថានមនុស្សនាម សក្យមុនី។

ធម៌ដែលសូត្រលោកសង្ឃមានច្រើនណាស់ គេក្រងនៅនឹងស្លឹកតាលព្រឹក្ស(១) ជិតស្នាមអក្សរខ្មៅ តែមិនសរសេរ ដោយជក់ រឺ ខ្មៅដុសឡើយ។ ខ្ញុំមិនដឹងសរសេរដោយអ្វីទេ(២)។ គេយកគ្រែស្នែង និងក្លស់ដងមាស រឺ ដងប្រាក់ មកសែងមកបាំងលោកសង្ឃដែរ ព្រោះស្តេចតែងពិគ្រោះនឹងព្រះសង្ឃ ចំពោះបញ្ហាណាដែលធំៗរបស់ស្រុកទេស ។ ប៉ុន្តែពុំឃើញមានដូនជីនៅក្នុងវត្តទាំងនោះទេ។
១ = បានជាខ្ញុំប្រែថា តាលព្រឹក្ស ព្រោះពាក្យដើម គេពុំទាន់បញ្ជាក់ច្បាស់ថា ស្លឹករឹតនៅឡើយទេ។ ២ = ការពិត គេចារដោយដែកចារ ហើយយកធ្យូងលាយប្រេងលុប ទើបបានជាស្នាមខ្មៅនេះ។

រីអែពួកតាបសដែលហៅ ប៉ាស៊ីវី នេះ ស្លៀកពាក់ជាអ្នកស្រុកធម្មតាដែរ តែមានជួតក្បាលកំនាត់ពណ៌ក្រហម របៀ បដូចពួកស្រី តារតា នៃជនជាតិម៉ុងហ្គោលដែរ តែទាបជាងបន្តិច។ ពួកនេះមានវត្តដូចព្រះសង្ឃពុទ្ធសាសនាដែរ តែមានទំហំតូចជាង។ លទ្ធិតាបសនេះ គ្មានអិទ្ធិពលខ្លាំងដូចសាសនាព្រះពុទ្ធទេ។ ពួកនេះគេគោរពចំពោះតែថ្ម មួយដុំធំ (៣) ដូចថ្មរូបអ្នកតាព្រះស្រុកដូច្នោះដែរ។ ប្រភពក្តី របៀបប្រតិបត្តិនៃពួកនេះក្តី ខ្ញុំពុំបានដឹងទេ។ ពួកនេះ មានដូនជី ហើយវិហារក៏ត្រូវអនុញ្ញាតអោយប្រក់ក្បឿងបានដែរ។ ពួកប៉ាស៊ីវី មិនបរិភោគរបស់អ្នកដទៃទេ ហើ

យមិនបរិភោគនៅចំពោះមុខទីសាធារណៈផង ហើយមិនសេពសុរាជាដាច់ខាត។ ខ្ញុំមិនដែលឃើញតាបសសូត្រធម៌ រឺក៏ធ្វើអំពើអ្វីជាប្រយោជន៍អ្នកផងច្បាស់នឹងភ្នែកម្តងណាឡើយ។

៣ = លោក ប៉េលីយោតយល់ថា ជាលិង្គ។

ចំនែកក្មេងៗកូនអ្នកស្រុកវិញ ដែលត្រូវការរៀនសូត្រ គេតែងយកទៅទុកដាក់រៀនជាមួយព្រះសង្ឃហើយបួសជាព្រះសង្ឃផង លុះដល់អាយុច្រើនក៏វិលត្រលប់មកកាន់ជីវភាពជាជនធម្មតាវិញ។ អែការល្អិតល្អន់ជាងនេះទៅទៀត ខ្ញុំមិនបានដឹងអោយច្បាស់លាស់ឡើយ។

## ២ - ប្រពៃណីអ្នកស្រុកចេនលា

### ៦. អំពីអ្នកស្រុក

តាមទំលាប់របស់ពួកមនុស្សដែលមិនទាន់ស៊ីវិល័យ ច្រើនតែមាន រូបឆោមខ្មៅគំរឹងគំរាំង មិននិយមនៅលើកោះដែលសំបូណ៌ដោយទឹកទេ ចូលចិត្តតែនៅក្នុងភូមិដាច់ស្រយាលពីគេ។ ទំលាប់បែបនេះជាការពិតណាស់។ចំនែកស្ត្រីក្នុងវាំង រឺ ស្រុកក្នុងត្រកូលថ្កុំថ្កើងវិញមានសាច់សដូចចាន ព្រោះតែគេមិនងាយបះនឹងកំដៅថ្ងៃឡើយ។ តាមធម្មតា ទាំងស្រី ទាំងប្រុស គ្មានស្លៀកដន្តប់អ្វីក្រៅពីសំពត់មួយផ្វាំងរុំព័ទ្ធភ្ជាប់នឹងចង្កេះនោះទេ។ គេលែងខ្លួនទុកដើមទ្រូងនៅកន្តាលវាលអែសក់បួង ជើងទទេ គ្មានស្បែកជើងឡើយ ទោះជាស្រុកមហេសីស្តេចក៏ដោយ

ព្រះមហាក្សត្រមានមហេសីប្រាំអង្គ គឺអគ្គមហេសីមួយ និងមហេសីសាមញ្ញបួនប្រចាំទិសធំទាំងបួនដែរ។ ចុះពីនោះមក ខ្ញុំលឺគេថាមានស្រីស្នំ បួនពាន់ រឺ ប្រាំពាន់នាក់ ហើយមានចែកជាជាន់ថ្នាក់ និងមិនអោយដើរចេញទៅណាផ្តេសផ្តាសឡើយ។ ខ្ញុំចូលទៅក្នុងវាំងពេលណា ក៏ឃើញស្តេចខ្មែរចេញមកជាមួយអគ្គមហេសី ហើយគង់ប្រថាប់នៅក្នុងស៊ុមមាស (១) នាល្វែងកន្តាលធំទូលាយ។ ចំនែកមន្ត្រីក្នុងវាំងវិញ នាំគ្នានៅអង្គុយក្នុងថែវព័ទ្ធជុំវិញតាមលំដាប់ថ្នាក់យសសក្តិរៀងខ្លួន ហើយនាំគ្នាលបមើលពីក្រោមស៊ុមមាសនោះមក។ ខ្ញុំបានចូលទៅឃើញម្តងគឺអោយតែនរណាមានកូនក្រមុំល្អច្បាស់ជាត្រូវគេហៅអោយនាំចូលទៅក្នុងវាំង។ ពួកស្រីនៅខាងក្រោយនេះដែលដើរច្រវាត់ចេញចូលបំរើ គេហៅថាតាំងកេលាង (ស្រីង្គារ) ។ ពួកនេះមានចំនួនមិនតិចជាងមួយពាន់ រឺពីរពាន់នាក់ទេ តែអាចយកប្តីរស់នៅជាមួយអ្នកធម្មតាបាន។ ស្រុកទាំងនេះសុទ្ធតែកោរសក់ពីលើថ្ងាសបន្តិច ហាក់ដូចជាពួកអ្នកបើកផ្លូវទឹកនៅស្រុកចិនខាងជើង ហើយគេលាបជាតិហិង្គុលនៅត្រង់ជើងសក់ក្បែរគុម្ពត្រចៀកទាំងសងខាង។ នេះហើយជាសញ្ញាសំគាល់ពួកតាំងកេលាង រឺ ជេនគលាន គឺមានតែពួកនេះហើយដែលអាចចូលក្នុងវាំងបាន អែអ្នកថយថោកពីនេះទៀតចូលទៅកាន់ផ្លូវខ្វាត់ខ្វែងខាងក្រោមប្រាសាទនោះមិនបានទេ។

១ = ល៊ុមមាសនេះហើយ ដែលយើងស្គាល់ម្តងមកហើយ ហើយយើងសន្មតថាជាបុស្បុកដែកជាទីប្រថាប់ក្នុងក្រលាព្រះកំនាល់។

ស្ត្រីអ្នកភូមិធម្មតា ក៏បួងសក់ដែរ ប៉ុន្តែគ្មានសៀតស្មៀតសក់ និង តុបតែងលំអមុខឡើយ។ នៅកដៃមានពាក់កងមាសនៅនឹងម្រាមដៃ មានពាក់ចិញ្ចៀនមាស។ ម្យ៉ាងទៀតពួកជេនគាឡាង និងអ្នកនៅក្នុងវាំងទាំងប្រុសទាំងស្រី សុទ្ធតែលា

បប្រេងក្រអូបដែលផ្សំឡើងពីជាជាតិឈើក្រអូប និងក្រលៀនប្រើស។

គ្រួសារទាំងអស់សុទ្ធតែគោរពប្រតិបត្តព្រះពុទ្ធសាសនា។

ក្នុងប្រទេសនេះ មានមនុស្សស្រីភេទខ្លះស្អាតៗ រាល់ថ្ងៃតែងដើរជាក្រុមដប់នាក់ រឺ លើសពីនេះ ទៅពាសពេញទីផ្សារជាញឹកញយណាស់ មានបំនងទាក់ទងពួកចិនៗ ដូរយករបស់មានតំលៃ ដែលជាទំលាប់មួយមិនល្អ មិនថ្លៃថ្នូរសោះ។

## ៧. អំពីស្ត្រីសំរាលកូន

ស្ត្រីស្រុកនេះ ក្រោយដែលសំរាលកូនរួចទៅ គេយកបាយក្តៅប្រលាក់លាយអំបិល ហើយញាត់ចូលទៅក្នុងទ្វារមាស លុះដល់បានមួយយប់មួយថ្ងៃ ទើបគេយកចេញមកវិញ។ ការធ្វើដូច្នេះ ជាហេតុនាំអោយមិនសូវមានជំងឺ និងអោយបានរួមទ្វារមាសតូចដូចជាស្ត្រីក្រមុំទៀត។ កាលខ្ញុំទើបដឹងរឿងនេះដំបូង ឆ្ងល់ថា ក្រែងមិនពិតដូច្នោះទេដឹង? ព្រោះថា បើបានជាមានប្តី និងមានកូនទៅហើយចុះម្តេចខ្លាចគេដឹងរឿងនេះទៀត? ប៉ុន្តែនៅនឹងផ្ទះដែលខ្ញុំសំនាក់នៅមានស្ត្រីម្នាក់សំរាលកូន ដែលជាហេតុនាំអោយខ្ញុំដឹងរឿងនេះច្បាស់លាស់ នៅក្រោយពេលសំរាលកូនហើយ មួយផ្នែកទៀត ស្រីនោះពកូនខ្ចីទៅមុជទឹកទន្លេ ដែលជាការចំលែកមិនដែលជួបប្រទះទេ។

នៅពេលដែលខ្ញុំទៅជួបគេម្តងណា គេតែងពោលថា ស្រីស្រុកនេះក្រាស់ដោយកាមតណ្ហាណាស់។ ក្រោយពេលដែលសំរាលកូនហើយមួយថ្ងៃ រឺ ពីរថ្ងៃប៉ុណ្ណោះ គេក៏រួមដំនេកជាមួយប្តីទៀតហើយ។ បើប្តីនោះបំពេញចំនង់ខ្លួនមិនបាទទេ នឹងត្រូវគេបោះបង់ចោលដូចពួកបួយឆេង(១) មិនខាន។ ប្រសិនប្តីនោះមានធុរៈទៅស្រុកឆ្ងាយអស់ច្រើនយប់ ចាប់ពីដប់យប់ឡើងទៅ ច្បាស់ជាត្រូវប្រពន្ធស្តីអោយថា ខ្ញុំមិនមែនស្ត្រីខ្មោចទេ តើអោយខ្ញុំដេកម្នាក់អែងម្តេចនឹងបាន?។ ខ្ញុំលឺថាមានស្ត្រីច្រើនណាស់រក្សាទុកសេចក្តីបរិសុទ្ធរបស់ខ្លួន។ ស្ត្រីៗច្រើនតែឆាប់ចាស់ណាស់ ពីព្រោះតែគេឆាប់មានប្តី ឆាប់មានកូនពេក។ មនុស្សដែលមានអាយុ ២០ រឺ ៣០ គឺប្រហែលគ្នានឹងជនជាតិចិនដែលមានអាយុ ៤០ រឺ ៥០ឆ្នាំដូច្នោះដែរ។

១ = បួយឆេង ប្រែថា មន្ត្រីទិញ គឺពួកដែលគេទិញដាច់ មិនអោយទៅនៅមានប្រពន្ធកូនឡើយ។

## ៨. អំពីស្ត្រីក្រមុំ

ពួកឪពុក ម្តាយដែលមានកូនស្រី តែងអោយពរកូនថា «សូមអោយអែងទៅអនាគតបានជាស្រីដែលមានប្តីរាប់ពាន់(២)។ កូនស្រីក្នុងគ្រួសារអ្នកមានចាប់ពិអាយុ ៧ ទៅ ៩ឆ្នាំ គ្រួសារអ្នកក្រខ្សត់រហូតដល់អាយុ ១១ឆ្នាំ គេនិមន្តលោក រឺតាបសមកបើកមុខកូនស្រីហៅថា ឆិនថាន់(៣)។

២ = ពរនេះ បានន័យថា អោយមានគេស្រលាញ់ច្រើន ដូចទំលាប់ពួក កួយ-ពុង បើមានកូនក្រមុំ គេអោយដេក នៅផ្ទះបាយ ទុកអោកាសពេលយប់អោយកំលោះចូលទៅស្គាល់លលួងចុះ។ ៣ = ឆិនថាន់ នេះមិនដឹងជាពាក្យ ដើមថាអ្វី រកប្រែអោយជាន័យច្បាស់ពុំទាន់ឃើញ។

ពិធីនេះ រាជការដាក់កំរិតអោយធ្វើមួយឆ្នាំម្តង នៅក្នុងខែដែលត្រូវនឹងខែទី៤ របស់ចិន ដោយរើសយកថ្ងៃណាមួយធ្វើតែ ម្តង។ អ្នកមានកូនស្រីដែលត្រូវធ្វើពិធីនេះ តោងជំរាបរាជការជាមុន ហើយអ្នករាជការ គេក៏អោយទៀនធំមួយដើមមក ទុកមុន និងមានគូសគំនូសមួយជាកំនត់សញ្ញាផង ថាដល់ពេលយប់ធ្វើពិធីនេះ បើដុតទៀនអស់ត្រឹមគន្លាក់នោះហើយ ត្រូវចាប់ពិធី ឆិនថាន់ ឡើង។

នៅមុនពេលដែលធ្វើពិធីនេះមួយខែ រឺ កន្លះខែ រឺ ដប់ថ្ងៃ អូវពុកម្តាយត្រូវជ្រើសរើស លោក រឺ តាបសណាមួយប្រកាន់ ទុកជាមុន ទោះបីនៅវត្តណាក៏ដោយ ក៏តែងតែមានគេទៅនិមន្តដែរ។

លោកគ្រូអង្គណាដែលសំខាន់ៗជាងគេ តែងតែត្រូវពួកមន្ត្រី រឺអ្នកមានគេនិមន្តទុកអស់ហើយ អែអ្នកក្រ ពុំអាចជ្រើសរើ សរកលោកបានតាមចំនង់ឡើយ។ មន្ត្រី រឺ អ្នកមាន គេបូជាលោកនូវសុរា អង្ករ កំនាត់សំពត់ ស្លាម្លូ និងគ្រឿងប្រាក់យ៉ាង ច្រើនរហូតដល់ទៅ ១០០អំរែកផង ហើយមានតំលៃប្រមាណមិនតិចជាងសាច់ប្រាក់ចិន ២០០រឺ ៣០០ តំលឹងឡើយ។ អ្នក មានរបស់របរតិច ក៏គង់ ៣០ - ៤០ រឺ ១០ -២០ អំរែកដែរ។ ដូច្នេះ គ្រួសារអ្នកក្រត្រូវរង់ចាំដល់កូនស្រីអាយុ ១១ឆ្នាំ ទើបចា ប់ធ្វើពិធីនេះ មកពីពិបាករករបស់របរទាំងនេះអែង។

មានអ្នកខ្លះ គេជួយលុយដល់កូនអ្នកក្រអោយធ្វើពិធីនេះដែលគេទុកជាការសាងកុសលមួយដែរ។ ក្នុងមួយឆ្នាំលោក រឺ តាបសមួយអង្គអាចទទួលនិមន្ត ធ្វើពិធីនេះអោយក្មេងស្រីបានតែមួយនាក់ទេ បើលោកយល់ព្រម នឹងអ្នកណាមួយហើ យមិនអាចទទួលអ្នកដទៃទៀតបានទេ។

នៅពេលយប់ដែលធ្វើពិធីនេះ គេមានរៀបចំគ្រឿងស៊ីផឹក និង ភ្លេងភ្លាត់ទ្រហឹងអឺងកង។ ក្រៅពីការជួបជុំញាតិមិត្តជិត ឆ្ងាយ គេមានសង់ធ្វើជារោងមួយ តំកល់រូបមនុស្ស រូបសត្វដែលសូនធ្វើអំពីដី។ អ្នកមានយសសក្តិ ធ្វើរូបនេះដល់ទៅជា ងដប់ អែអ្នកធម្មតា យ៉ាងហោចមកក៏មានបី រឺ បួនដែរ។

ចំពោះអ្នកដែលទាល់ក្រខ្លាំងវិញ គ្មានធ្វើរូបនេះទេ គិតតែរៀបពិធីតែម្តងទៅ លុះដល់ពេលគ្រប់ ៧ថ្ងៃ ទើបគេរុះរោង

នេះចេញ។ នៅយប់ដែលធ្វើពិធីនោះទៀតគេយកគ្រែស្នែងទៅនិមន្តលោកហើយបាំងក្លស់ និង លេងភ្លេងដង្ហែនាំយកមក។ គេមានកូនតូបពីរដូចគ្រែស្នែងដែរ ដែលបិទបាំងលំអដោយព្រៃពណ៌ភ្លឺព្រាល។ តូបមួយសំរាប់អោយកូនស្រីនោះអង្គុយអែតូបមួយទៀត សំរាប់លោក រី តាបសគង់សូត្រធម៌ តែខ្ញុំមិនដឹងលោកសូត្រអ្វីឡើយ។ ពេលនោះភ្លេងក៏ប្រគំ លឺគឹកកងរំពងដែរ។ ខ្ញុំលឺថាយប់នេះគ្មានត្រនមអ្វីទេ គ្រាន់តែដឹងថា ដល់ពេលវេលាភ្លាមលោក រី តាបសនោះក៏ចូលទៅក្នុងបន្ទប់ជាមួយកូនស្រី ហើយលូកដៃរបស់លោកផ្ទាល់ទៅយករបស់កូនស្រីដាក់ទៅក្នុងស្រា(១)។ ខ្លះទៀតថា យកមកភ្លក្សគ្រប់គ្នា ហើយខ្លះថា លោកក៏រួមរ័កជាមួយកូនស្រីក្នុងពេលនោះ តែខ្លះថា អិតមានទេ។ រឿងនេះ គេមិនអោយពួកចិនបានឃើញផ្ទាល់ទេ ហេតុនេះ ទើបខ្ញុំមិនអាចបានដឹងនូវការពិតឡើយ។

១ = ត្រង់នេះ អត្ថបទដើមក៏និយាយមិនច្បាស់សេចក្តីដែរ យើងប្រែអោយនៅន័យត្រឹមតាមឃ្លាដើមជា (អក្សរចិន)។ ត្រង់នេះលោក ប៉េលីយោត ប្រែថា : Il lade flore avec la main et recueille ses premices dans du vin។ អ្នកបកប្រែសូមបញ្ជាក់ថា : រឿងរ៉ាវក្នុងវគ្គនេះ ពុំដែលលឺក្នុងទំនៀមខ្មែរទេ ប៉ុន្តែយើងប្រែតាមតែអត្ថបទដើមប៉ុណ្ណោះ មិនហ៊ានបំបាត់ចោលឡើយ។

លុះពេលទៀបភ្លឺទើបគេដង្ហែលោកដោយគ្រែស្នែងមានភ្លេងនឹងបាំងក្លស់ នាំយកទៅវិញ ហើយគេយករបស់ល្អៗ មានព្រៃពណ៌ជាដើម ទៅធ្វើជាថ្នូរលស់យកកូនស្រីនោះមកវិញ។ បើពុំធ្វើដូច្នេះទេ កូនស្រីនេះមិនអាចយកទៅអោយមានប្តីដទៃទៀតបានឡើយ ព្រោះនៅជាកម្មសិទ្ធិរបស់លោកនៅឡើយ។

ពេលដែលខ្ញុំបានឃើញរឿងរ៉ាវនេះ គឺនៅថ្ងៃ៦ ខែទី ៨ នៃឆ្នាំតេងអីវ ក្នុងរជ្ជការស្តេច តាយតេក (គ.ស ១២៩៧)នៅពេលដែលមុនធ្វើពិធីនេះ កូនស្រីត្រូវនៅដេកក្នុងបន្ទប់ជាមួយអូវពុកម្តាយ លុះដល់ធ្វើពិធីនេះរួចហើយ កូនស្រីត្រូវបែកទៅដេកបន្ទាប់ដទៃ ហើយនាងចង់ទៅដេកកន្លែងណាក៏បាន តាមចិត្តចង់ អិតមាននរណាតាមមើលគយឃ្លាំឡើយ។

ចំពោះរឿងអាពាហ៍ពិពាហ៍វិញ ពិតមែនតែមានតំរូវអោយជូនលុយកាក់ជាច្រើន ប៉ុន្តែគេមានអនុគ្រោះច្រើនដែរ។ មានខ្លះគេអាចដេកនៅរួមរ័កនឹងគ្នាជាមុនទៅហើយទើបរៀបការជាក្រោយក៏បាន។ តាមប្រពៃណីគេមិនចាត់ទុកការណ៍នេះជាការគួរខ្មាសអៀន រឺ ចំលែកឡើយ។

នៅយប់ដែលធ្វើពិធី ឆិនថាន នោះ ជូនកាលនៅតែតាមផ្លូវមួយមានដល់ទៅដប់ផ្ទះអែនោះ រៀបធ្វើពិធីនេះ។នៅតាមទីក្រុងអ្នកណាហ៊ានដើរកាត់ហ្វូងពិធី ពីមុខលោក រី តាបសទាំងនេះ ច្បាស់ជារង្វេងវង្វន់ផ្លូវហើយ ណាមួយលឺគឹកកង

ស័ព្ទសូរភ្លេងគ្មានចន្លោះត្រង់ណាទេ។

## ៩. អំពីទាសាទាសី

គេសុទ្ធតែទិញមនុស្សព្រៃ(១) យកមកបង្ខំអោយធ្វើជាទាសាទាសី។ អ្នកដែលមានច្រើន គឺមានទាសាទាសីដល់ទៅជាងមួយរយនាក់ អែអ្នកដែលមានតិច ក៏ត្រឹម១០ - ២០នាក់ដែរ លើកលែងតែអ្នកក្របំផុតទើបគ្មានសោះ។ចំនែកមនុស្សព្រៃទាំងនោះ គឺអ្នករស់នៅក្នុងព្រៃភ្នំ មានជាវង្សត្រកូលមួយហៅថាអាចោរ «ចុង»(២) (ជង?)។ពួកនេះបើមកនៅកន្លែងណាហើយ មិនហ៊ានចេញដើរទៅណាក្រៅផ្ទះឡើយ។ ពួកអ្នកស្រុកក្រុង គេឈ្លោះគ្នា គេជេរគ្នាថា អាចុងៗ ដូច្នេះ គេខឹងខ្លាំងណាស់ ព្រោះទុកជាការមើលងាយយ៉ាងធ្ងន់។ ក្មេងៗមានកំលាំងពេញលក់បានតំលៃមួយរយ «ប៉ូវ»(៣) បើចាស់ៗខ្សោយកំលាំងបានតែ៣០ រឺ ៤០ទេ។

១ = មនុស្សព្រៃនេះ គឺពួកអ្នកស្រុកដើមដែលរស់នៅដោយព្រៃមិនទាន់មានទទួលស៊ីវិល័យ គេកៀរចាប់មកលក់
២ = លោកប៉េលីយោត ក៏សន្និដ្ឋានថា ពាក្យនេះមកពី «ជង» ដែរ ហើយអះអាងថាជាពាក្យដែលអានតាមសំលេងចិនក្នុងសតវត្សទី១៣។ ៣ = លោកប៉េលីយោត បន្ថែមន័យថា D'étoffe ពុំដឹងជាមានកំនត់ប៉ុន្មានទេ តែនេះយើងប្រែតាមពាក្យដើមថា ប៉ូវ ដែលប្រែថា កំនាត់សំពត់។

ពួកនេះ គេអោយនៅតែក្រោមផ្ទះ លុះត្រាមានការប្រើចាំបាច់ទើបគេអនុញ្ញាតអោយឡើងលើផ្ទះ ហើយត្រូវអោយលុតជង្គង់លើកដៃសំពះគេសិន ទើបអាចអោយដើរចូលក្នុងផ្ទះបាន។ គេហៅម្ចាស់គេថា ប៉ាថូ(១) ហៅម្ចាស់ស្រីថា មី(២)។ ប្រសិនបើមានកំហុសត្រូវគេវាយដំវិញ ពួកនេះសុខចិត្តជ្រប់មុខបន្ទោយអោយគេវាយតាមចិត្ត មិនហ៊ានរើបំរះឡើយ។ ពួកនេះស្រី-ប្រុស គេយកតែគ្នាគេជាប្ដី-ប្រពន្ធ គ្មានសិទ្ធិយកអ្នកដទៃឡើយ។ បើមានពួកចិនទៅនៅស្រុកនោះយូរ លួចរួមរ័កជាមួយស្ត្រីពួកនោះ ដោយការស្រេកឃ្លានកាមតណ្ហា ហើយម្ចាស់គេទាន់ នោះអ្នកផងគេលែង អោយចិននេះអែងអង្គុយជាមួយគេហើយ ព្រោះខ្លួនលួចលាក់ជាមួយពួកទាសៈ។បើពួកទាសៈទាំងនេះ ទាក់ទងលួចលាក់ជាមួយអ្នកក្រៅ រហូតដល់មានផ្ទៃពោះ កើតបានជាកូនទៅ ក៏ចៅហ្វាយនាយអិតសួររកហេតុផលឡើយ។ បានជាគេមិនសួរមកពីគេយល់ថា បើទាសៈនោះ កាលណាបានកូនមក នឹងបានផលដល់គេ ព្រោះថ្ងៃក្រោយគេនឹងចំរើនទាសៈឡើងទៀត។ បើទាសៈណាលួចរត់ ហើយគេតាមចាប់បានមកវិញ គេត្រូវយកមកសាក់មុខ ចំកន្ទាលថ្ងាសពណ៌ខៀវ ជាគ្រឿងចំនាំ ហើយគេដាក់ឃ្នាងជាប់នឹងក ជូនដាក់ឃ្នាងជាប់ទាំងដៃជើងទៀតផង។

១ = ទំនងជាមកពី ប៉ាតាវ ដែលនៅសល់ក្នុងភាសាជនជាតិដើមចារ៉ាយ ហៅអូវពុក។ សំលេងចិនអានថា មី សំដៅពាក្យ

ហៅម្ដាយថា មេ។

### ១០. អំពីភាសា

ភាសាចិន មានសំលេងប្រហាក់ប្រហែល នឹងភាសាអ្នកស្រុកនេះដែរ តែនិយាយប្រស្រ័យស្ដាប់គ្នាមិនបានទេ ស្រុកនេះមានភាសាមួយពិសេស ទោះបីជាភាអ្នកជិតខាងខ្លួនដូចជាចាម រឺ សៀម ក៏មិនអាចដូចគ្នាស្ដាប់គ្នាបានឡើយ។ ១គេថាមួយ ២ ថាព័ក ៣ថា បេក ៤ថា ពួន ៥ថា ពុណាំ ៦ថា ពុំណាំមួយ ៧ពុណាំព័ក ៨ពុណាំបេក ៩ពុណាំពួន ១០ថាតាប់។ គេហៅអូវពុកថា ប៉ាថូ អូវពុកធំ អូវពុកមា ក៏ហៅប៉ាថូដែរ។ ម្ដាយ គេហៅ មី អែម្ដាយមីង និង ស្ត្រីអ្នកជិខាងក៏គេហៅមីដែរ។ បងស្រី ប្រុស ហៅថាប៉ង ប្អូនប្រុសស្រី ហៅថា ផូវអ៊ីង។ មាខាងម្ដាយហៅថា អាកឡៃ អែប្ដីរបស់ម្ដាយមីងខាងអូវពុកហៅថា ពូឡៃ។ គេប្រើពាក្យយកខាងចុងជាដើមបញ្ច្រាស់គ្នា។ អុបមាដូចពាក្យ នេះមនុស្សទាសាំ ជាប្អូន គេថាផូងអ៊ីងទាសាំ ពាក្យថា នេះមនុស្ស លីស៊ីមាខាងអូវពុក គេថា ងាន ឡៃលីស៊ី អុបមាមួយទៀត ដូចគេហៅចិនថា ពីស៊ី ហៅមន្ត្រីថា ប៉ាតេង ហៅអ្នកប្រាជ្ញថា ប៉ានឃាប លុះដល់គេចង់ថាមន្ត្រីចិន រឺអ្នកប្រាជ្ញចិន គេមិនថា ពីស៊ីប៉ាតេង រឺ ពីស៊ីប៉ានឃាបទេ គេទៅជាប្រើថា ប៉ាតេងពីស៊ី រឺ ប៉ានឃាមពីស៊ី(១) ទៅវិញ។

១ = ប៉ាតេងពីស៊ី = មន្ត្រីចិន។ ប៉ានឃាបពីស៊ី = អ្នកប្រាជ្ញចិន។

ទាំងនេះ គ្រាន់តែលើកយកជាអុទាហរណ៍គោលៗទេ។ ម្យ៉ាងទៀត គឺមន្ត្រីគេនិយាយតាមបែបមន្ត្រី អ្នកប្រាជ្ញនិយាយគ្នាតាមភាសាអ្នកប្រាជ្ញ លោកសង្ឃ រឺ តាបស ក៏មានពាក្យសំដីប្រើរបៀបខ្លួនជាសង្ឃ ជាតាបស អែអ្នកស្រែចំការក៏និយាយប្លែកតាមបែបរបស់គេដែរ មិនប្លែកអ្វីពីរបៀបប្រើភាសាអ្នកស្រុកចិន។

### ១១. អំពីមនុស្សព្រៃ

មនុស្សព្រៃមានពីរបែប។ មួយពួកជាពួកចេះនិយាយភាសាអ្នកស្រុកស្ដាប់គ្នាបាន គឺពួកមនុស្សព្រៃលក់ខ្លួនជាទាសៈ បំរើគេនេះអែង។ មួយទៀត គឺពួកមនុស្សព្រៃដែលនិយាយស្ដាប់ភាសាគ្នាមិនបាន គ្មានរវល់នឹងការចំរើន។ ពួកនេះ គ្មានចេះធ្វើផ្ទះជ្រកនៅទេ តែងនាំគ្នាទាំងគ្រួៗដើររស់នៅតាមភ្នំ។ ក្បាលគេមានពាក់អ្វីម្យ៉ាងធ្វើពីដីរាងដូចឆ្នាំង។ បើដើរទៅជួបនឹងសត្វព្រៃ គេបាញ់នឹងព្រួញ រឺ ពួយនឹងលំពែង បានសត្វនោះមក ក៏គូសដុំថ្មយកភ្លើង ចំអិនសត្វ រួចអង្គុយជុំកង់ចែកគ្នាស៊ី។ រួចហើយដើរទៅទៀត។ ពួកនេះកាចសាហាវណាស់ តែងសំលាប់ក្រុមជាមួយ ហើយចេះផ្សំថ្នាំពិស ពូកែសក្តិសិទ្ធណាស់។ នៅដីវាលជិតខាងកន្លែងនៅ គេមានដាំសន្តែកគួ ដើមក្រវាញ និង ដើមកប្បាស ត្បាញសំពត់ជាវិជ្ជាជីវៈ។ សំពត់របស់គេនោះ សាច់ក្រាស់គ្រើម ហើយមានពណ៌ក្រវេមក្រវាមណាស់ផង។

## ១២. អំពីអក្សរសាស្រ្ត(១)

លិខិតធម្មតា និងអត្ថបទទាំងអស់ ដូចជាអែកសារផ្លូវការជាដើម សុទ្ធតែសរសេរលើស្បែកសត្វប្រើស រមាំង រឺ ស្បែកដទៃទៀត ដែលគេយកមកហាលស្ងួតលាបពណ៌ខ្មៅ។ គេកាត់ស្បែកនោះអោយមានទំហំធំ រឺ តូច ទៅតាមសេចក្តីត្រូវការ និងយកម្សៅម្យ៉ាងមកប្រើ មានសន្ឋានដូចដីសនៅស្រុកចិន ដោយលញ់អោយវែង ចិតចុងស្រួចគេហៅថា សោ(២) ហើយគេសរសេរដោយដៃ បានជាប់ជិតល្អណាស់ មិនងាយនឹងរលុបឡើយ។ កាលណាគេសរសេរហើយ គេយកដីសនោះមកសៀតនឹងត្រចៀក នាំអោយគេចំនាំបានថា អ្នកនេះហើយជាអ្នកសរសេរ។ បើសរសេរហើយត្រូវការលុបវិញ តោងប្រើរបស់ទទឹកយកមកជូតទើបរលុបអក្សរនោះទៅវិញ។ អក្សរនេះ មានសន្ឋានដូចអក្សរជនជាតិហ្វយតូវ (តួរក៍) ដូច្នេះដែរ។ ការសរសេរជាលិខិតអ្វីក៏ដោយ គេសុទ្ធតែសរសេរពីក្រោយទៅមុខ មិនមែនសរសេរពីលើចុះក្រោម។ ខ្ញុំលឺអ៊ាសាយហាយ៉ា និយាយថាស្រះនៃអក្សររបស់គេ ស្រដៀងគ្នានឹងអក្សរជាតិមុងហ្គោលដែរ មានប្លែកគ្នាតែពីរបីប៉ុណ្ណោះ។ កាលនោះគ្មានអត្ថបទបោះពុម្ពទេ ប៉ុន្តែមានអ្នកនិពន្ធ និងអ្នកតែងកាព្យពេចន៍ដែរ។

១ = លោកប៉េលិយោត ប្រែត្រង់នេះថា Ecriture ។ តែន័យយើងថានេះទូលាយជាង ព្រោះតំរូវតាមអក្សរចិន (?) ។

២ = ត្រង់នេះលោកប៉េលិយោតថា ហៅថាសូ ទៅវិញ។ តែបើលឺតាមចាស់ៗនិយាយតៗមកថា គេសរសេរនឹងដីសពង គឺដីសុទ្ធ តែដូចម្សៅ។

# ៣ - ប្រពៃណីអ្នកស្រុកចេនលា

## ១៣. អំពីពេលបុណ្យចូលឆ្នាំ

គេយកខែទីត១០ របស់ចិនធ្វើខែទី១ ហើយខែនោះមានឈ្មោះថាកាតិក (កក្តិក)(១)។ នៅពីមុខវាំងគេសង់វេទិការមួយយ៉ាងធំ ដែលអាចដាក់បានមនុស្សមួយពាន់នាក់ ហើយគេចងប្រទីបផ្កាលា និងផ្កាផ្ទីជាដើម លំអនៅលើថ្នាក់នោះ។ នៅពីមុខដែលឃ្លាតពីទីនេះប្រមាណជា ២០០ហាត្ថ មានទីលានមួយទៀត គេបន្តឈើធ្វើជារោងរន្ទា ដែលមានកំពល់ដល់ទៅជាង២០០ហាត្ថ។ ក្នុងយប់នោះគេអុជកាំជ្រួច រន្ទា ផាវបី-បួន រឺ ប្រាំកន្លែង។ នៅក្នុងរោងនោះ ស្តេចក៏យាងចេញមកទត កាំជ្រួច រន្ទា និង ផាវ ដែលគេអុជនៅខាងក្រៅចំងាយ ១០០លី តែគេអាចមើលឃើញ និងស្តាប់សូរយ៉ាងច្បាស់ លីខ្លាំងមើលតែកាំភ្លើងធំទ្រហឹងខ្ទរខ្ទារពេញតែទីក្រុង។

១ = បានជារាប់ពីខែកក្តិត ព្រោះជំនាន់ដើមគេរាប់រនោចមុនខ្នើត គឺពី១រោចខែកក្តិក ទៅជាដើមឆ្នាំខែលេខ ១។

មន្ត្រីនិងរាជវង្សទាំងអស់នាំគ្នាកាន់ទៀន និងម្លូស្លាដែលជាហេតុនាំអោយចំនាយប្រាក់យ៉ាងច្រើន។ នៅក្នុងពិធីនេះ ស្តេចបានអញ្ជើញពួកទូតបរទេសទៅចូលរួមផងដែរ។ គេធ្វើដូចនេះអស់រយៈពេលកន្លះខែទើបបានចប់។

នៅក្នុងខែនិមួយៗ សុទ្ធតែមានពិធីបុណ្យដែរ ដូចជានៅខែទី៤ គេបោះឈូង ខែទី៩ ធ្វើអាបឡ្មាក់(២) ពិធីនេះគេហៅប្រជុំមនុស្សចូលក្រុង ហើយហាត់ក្បួនដើរដង្ហែកាត់មុខវាំង។ ខែទី៥ គេទទួលយកទឹកមន្តព្រះពុទ្ធ ពីគ្រប់ទីជិតឆ្ងាយទាំងអានាចក្រ យកមកស្រោចស្រង់ថ្វាយព្រះរាជជំរះកាយ ហើយអុំនាវានៅលើគោក (អុំទូកគោក) អែស្តេចយាងឡើងលើប្រាសាទទតមកពិធីនេះ។ ខែទី៧ ធ្វើពិធីដុតភ្នំស្រូវ។ ពេលនោះស្រូវទើបនឹងទុំថ្មី គេទទួលយកមកតាមទ្វារខាងត្បូងហើយគេគរដុត ថាជាការបូជាចំពោះព្រះពុទ្ធ។ មានស្រីៗច្រើនណាស់ជិះរទេះ រឺ ដំរី នាំគ្នាមកមើលពិធីនេះ អែព្រះរាជាមិនចេញមកទតពិធីនេះទេ ទ្រង់គង់នៅអែព្រះដំនាក់។ ខែទី៨ ធ្វើពិធីអៃលាំ(៣) ពិធីនេះគេរាំរែក។ គេចាត់អ្នករាំនិងអ្នកភ្លេងពូកែៗអោយចូលទៅរាំអៃលាំក្នុងវាំងរាល់ៗថ្ងៃ។ ក្រៅពីនេះមានប្រជល់ជ្រូក និងប្រជល់ដំរីទៀត។ ពិធីនេះស្តេចក៏អញ្ជើញពួកទូតប្រទេសក្រៅចូលទស្សនាផងដែរ។ គេធ្វើដូច្នេះរហូតដល់គ្រប់ដប់ថ្ងៃ។ អែដទៃទៀត ខ្ញុំមិនបានកត់ត្រាអោយច្បាស់លាស់ទេ។ អ្នកស្រុកនេះ ក៏មានអ្នកចេះវិជ្ជាតារាសាស្ត្រដូចចិនដែរ អាចនឹងដេញរកថ្ងៃខែណាធំតូច រឺសូរ្យគ្រាស ចន្ទគ្រាសដែរ តែថ្ងៃខែធំតូចនេះ មិនដូចគ្នានឹងប្រទេសចិនទេ។ បើឆ្នាំណាជាឆ្នាំអធិកមាស គេក៏មានលើកខែដែរ។ ខែដែលត្រូវលើកនោះគឺខែទី៩(៤) ប៉ុន្តែខ្ញុំមិនដឹងការនេះសព្វគ្រប់ទេ។ ក្នុង១យប់ គេចែកចេញជាប្រាំយាម។ ប្រាំពីរថ្ងៃរាប់ជាមួយជុំ គឺដូចគ្នានៅស្រុកចិន ហៅថា កាយ-ពី-ភៀន-ជូ។

២ = លោកប៉េលីយោតប្រែថា Ya-lie ហើយចុះសេចក្តីយល់ថា Ràp Riep។ ៣ = លោកប៉េលីយោតប្រែថា Gnai-lan (Ràm) ៤ = តាមពិតយើងលើកខែទី៨ គឺខែអាសាធ ប៉ុន្តែនេះ គឺលោកជីវក្ខាន់និយាយតាមខ្មែរជំនាន់ដើម ដែលរាប់ពី១រោច ខែអាសាធ ទៅដល់ ១កើតខែស្រាពណ៍ចាត់ជាខែទី៨។

អ្នកស្រុកនេះ គ្មានប្រើនាមត្រកូល(សែ) គ្មានឈ្មោះ ហើយមិនចេះកត់ថ្ងៃខែកំនើតផង ភាគច្រើន គេយកឈ្មោះថ្ងៃដែលកើត ហៅជាឈ្មោះមនុស្ស។ តាមក្បួនយាមថា ក្នុងមួយសប្តាហ៍ មានពីរថ្ងៃល្អបំផុត បីថ្ងៃល្មមធម្ម ពីរថ្ងៃអាក្រក់ ហើយថ្ងៃណាត្រូវចេញដំនើរបែរមុខទៅទិបូព៌ រឺត្រូវឆ្ពោះទៅទិសបស្ចឹម។ ពួកស្រីៗក៏ចេះរាប់ថ្ងៃខែដែរ។ ឆ្នាំទាំង១២ មានយកសត្វជាជំនាងដូចឆ្នាំរបស់ចិនដែរ តែហៅឈ្មោះខុសគ្នា អុបមាដូចគេហៅឆ្នាំសេះថា ប៉ុកសាយ ឆ្នាំមាន់ហៅថា ឡាក់ ឆ្នាំជ្រូកហៅថា ចេកលូ និងឆ្នាំគោហៅ គូជាដើម។

## ១៤. អំពីការកាត់ក្តី

រឿងប្រជារាស្ត្រក្តីក្តាំគ្នា ពិតមែនតែជាការតូចតាច ប៉ុន្តែជាការមួយគួរអោយចង់ដឹងចង់លឺដែរ។ រឿងក្តីក្តាំរបស់រាស្ត្រ សុទ្ធតែឡើងគាល់រហូតដល់ស្តេចអោយជំរះក្តី។ ដើមឡើយ ស្តេចអិតមានវាយតប់ដោយរំពាត់ធំ រឺ តូចឡើយមានតែពិន័យជាមាសប៉ុណ្ណោះ។ បើអ្នកនោះមានៈមិនព្រមធ្វើតាម រឺ មានទោសធ្ងន់នោះ គេចាប់ចងយកទៅប្រហារជីវិតដែរ គ្រាន់តែនាំចេញទៅទ្វារខាងលិច ហើយអោយជីករន្តៅកប់អ្នកទោសនោះ និង យកដី រឺ ថ្មកប់គ្របពីលើប៉ុណ្ណោះ។

ទោសស្រាលបន្ទាប់មក គឺកាត់ម្រាមដៃជើង មានខ្លះត្រូវគេកាត់ច្រមុះចោលក៏មានដែរ។ រឿងសហាយស្មន់ និងលេងល្បែង អិតមានហាមឃាត់ទេ។ បើប្តីរបស់ស្រីដែលមានសហាយនោះដឹង គេយកឈើពីរ ទៅចងគាបជើងរបស់ប្រុសសហាយនោះ អោយឈឺស្ទើរស្លាប់។ បក្សពួកខាងប្រុសទាំងប៉ុន្មានត្រូវរួចខ្លួន។ អែអ្នកដែលផ្តើមគំនិតបោកប្រាស់គេត្រូវមានទោសដែរ។ បើមានមនុស្សស្លាប់នៅនឹងទ្វារកំពែង គេយកខ្សែចងអូសទៅទីវាលក្រៅក្រុង ហើយសម័យនោះគ្មានការពិនិត្យសាកសព្វអ្វីទេ។ បើគេចាប់បានចោរក៏អាចនាំទៅឃុំឃាំងសួរចំលើយដែរ តែមានការគួរអោយអស់សំនើច គឺថា បើគេសង្ស័យថាជននោះជាចោរ ហើយជននោះមិនព្រមទទួលសារភាព គេនឹងយកខ្ទះមកដាំខ្លាញ់អោយក្តៅមែនទែន ហើយគេអោយជននោះលូកដៃទៅក្នុងខ្លាញ់កំពុងពុះនោះអែង។ បើជននោះជាចោរមែនក៏ត្រូវរលាករលួយដៃ បើមិនមែនជាចោរទេ អិតមានរលាកឡើយ។ ម្យ៉ាងទៀត បើមានគ្រួសារពីរក្តីក្តាំគ្នា ហើយរកកាត់សេចក្តីរកនរណាត្រង់ រឺ វៀចមិនមិនកើត គេធ្វើដូច្នេះ នៅពីមុខវាំង មានប្រសាទថ្មតូចៗ ១២ខ្នង ហើយគេបញ្ជាកូនក្តីអោយចូលទៅអង្គុយក្នុងប្រសាទនោះមួយម្នាក់។ គេអង្គុយតាំងពីមួយថ្ងៃ ពីរ បី រឺ បួនថ្ងៃទៅ បើនរណាដែលជាអ្នកធ្វើខុសនឹងច្បាប់នោះ

ពិតជាមានភស្តុតាងលេចឡើងមិនខាន គឺបើមិនចេញកមរមាស់ទេ ក៏ក្តៅផ្តាសាយដែរ។ អែអ្នកទៀងត្រង់អិតមានផុលរមាស់អ្វីឡើយ។ ការវិន័ច្ឆ័យដូច្នេះ គេហៅថា គុកស្វគ៌។ រឿងដូច្នេះបានមកពីព្រះភូមិរក្សាទឹកដីរបស់គេ ពូកែសក្តិសិទ្ធិណាស់ ទើបគេអាចធ្វើដូច្នេះទៅកើត។

១ =គុកស្វគ៌ គឺជាគុកមួយដែលសក្តិសិទ្ធ ដូចទេវតាមកកាត់ក្តីនេះអោយ។

## ១៥. អំពីជំងឺស្រែង(២)

អ្នកស្រុកមានកើតជំងឺស្រែងច្រើនគ្នាណាស់ មកពីគេចូលចិត្តមុជត្រាំក្នុងទឹក ហើយអុស្សាហ៍លាងសក់ក្បាល តែងមានកើតជំងឺស្រែងច្រើនណាស់។ នៅតាមផ្លូវថ្នល់ ពួកនេះមិនសូវអៀនខ្មាសទេ។ ខ្ញុំលឺគេថា ពួកទាំងនេះតែគេរួមភេទគ្នាភ្លាមគេចុះទៅងូតទឹកហើយ ដូច្នេះតែងមានជំងឺមួល បន្តាលអោយស្លាប់អស់៨-៩នាក់ដែរក្នុងបន្ទាមួយពាន់នាក់។ នៅទីផ្សារមានលក់ថ្នាំសំរាប់កែរោគដែរ តែមិនដូចថ្នាំចិនទេ មិនដឹងជាថ្នាំអ្វីឡើយ ថែមទាំងមានគ្រូមន្តអាគមដើរព្យាបាលរោគអោយគេ ជាការគួរអស់សំនើចណាស់។

១ = លោកប៉េលិយោត ប្រែថាឃ្លង់ ប៉ុន្តែតាមន័យអក្សរចិន ប្រែអោយចំគឺស្រែង។ បើថាឃ្លង់ដូចជាមិនមែន ព្រោះកើតឃ្លង់អែណាដល់ទៅពេញស្រុក បើឃ្លង់មែន មិនងាយមើលជាទេ។ បើថាស្រែងនោះសមមែន ព្រោះជំងឺនេះច្រើនបន្តាលមកពីការកខ្វក់។

## ១៦. អំពីមរណភាព

មនុស្សចាស់គេអិតមានដាក់ក្តារមឈូសទេ គេយកតែកន្ទេលក្រាលពីក្រោម យកកំនាត់សំពត់គ្របពីលើ ហើយគេយកទៅព្រៃហើយ។ កាលពីដើម គេក៏ប្រើទង់ព្រលឹង និង ភ្លេងភ្លាត់ហែខ្មោចដែរ ហើយគេលីងលាចពីរមុខ បាចតាមផ្លូវនាំមុខខ្មោច លុះលែងទៅដល់ក្រៅក្រុងដល់កន្លែងស្ងាត់ គេក៏ដាក់ចោលខ្មោចនោះហើយត្រលប់មកវិញ។ បើមានសត្វខ្លែង រឺ តិរច្ឆានអ្វីដទៃទៀតស៊ីខ្មោចនោះអស់មួយរំពេចទៅ គេថាអូវពុកម្តាយនោះ មានភ័ពបានសុខសប្បាយល្អណាស់ តែបើគ្មានសត្វស៊ីសោះ រឺ មានស៊ីដែរ តែមិនអស់វិញ គេបែរជាយល់ថា អូវពុកម្តាយនេះ មានពៀរមានទោសទើបបានដូច្នេះ។

លុះមកដល់គ្រាអិល្លូវនេះ មានគេយកខ្មោចទៅដុតបូជាខ្លះៗហើយ។ ពួកអ្នកដែលមានជាប់ពូជជាកូនចិន អូវពុកម្តាយស្លាប់ទៅគេអិតស្លៀកពាក់សកាន់ទុក្ខទេ។ ប្រុសគ្រាន់តែកោរសក់ ក៏ចាត់ជាការកាន់ទុក្ខហើយ។ ចំនែកស្តេចវិញ មាន

ប្រាសាទសំរាប់កប់ ប៉ុន្តែមិនដឹងជាកប់ខ្លួនទាំងមូល រឺ កប់តែឆ្អឹងទេ។

## ១៧. អំពីការភ្ជួរដាំ

ប្រហែលជាក្នុងមួយឆ្នាំ គេអាចសាបព្រោះនិងច្រូតស្រូវបានបី រឺ បួនលើក ពីព្រោះរដូវទាំងបួនមានធាតុអាកាសស្រួលល្អ ដូចជាខែទី ៥ ទី ៦ ដែរ។ ម្យ៉ាងទៀត ស្រុកនេះ គេមិនស្គាល់ដូចម្តេចថាធ្លាក់ព្រិល រឺ ទឹកកកឡើយ។ ស្រុកគេ កន្លះឆ្នាំភ្លៀង កន្លះឆ្នាំអិតមានភ្លៀងសោះ។ ចាប់តាំងពីខែទី៤ ដល់ទី៩ តែដល់ពេលរសៀលមានភ្លៀងធ្លាក់រាល់ថ្ងៃ ទឹកនៅក្នុងសមុទ្រទឹកសាប (ទន្លេសាប) ជោរឡើងមានកំពស់ ៧០ -៨០ ហត្ថ។ ដើមឈើធំៗលិចនៅសល់តែចុង អែពួកអ្នកស្រុករស់នៅក្បែរមាត់ទឹកនោះបាននាំគ្នារើលំនៅមកជ្រកខាងក្រោយភ្នំវិញ។

ចាប់ពីខែទី១០ ដល់ខែទី៣ នៃឆ្នាំថ្មី គ្មានភ្លៀងមួយដំនក់ទេ នៅក្នុងសមុទ្រទឹកសាបនោះ ធ្វើដំនើរបានតែកូននាវាតូចៗទេ។ ត្រង់កន្លែងទឹកជ្រៅ មានជំរៅត្រឹម ៣ រឺ ៥ហត្ថប៉ុណ្ណោះ។ ពេលនោះអ្នកស្រុករើលំនៅទៅនៅមាត់ទឹកធ្វើការភ្ជួរដាំវិញ។ ចំពោះស្រូវ ដល់ទៅពេលណាទុំ ក៏ត្រូវពេលទឹកឡើងដល់ល្មម។ គេសាបព្រោះដាំតាមកន្លែងដីរបស់គេរក្សារៀងខ្លួន។ គេភ្ជួរស្រែដោយមិនបាច់ប្រើគោទេ។ ចប និង កន្ត្រៀវរបស់គេ ពិតមែនតែមានសន្ឋានប្រហាក់ប្រហែលគ្នានឹង របស់ចិនដែរ តែមិនដូចគ្នាឡើយ។

មានស្រែព្រៃមួយបែបទៀត គេមិនព្រោះស្រូវធម្មតាទេ ស្រូវដែលគេព្រោះនោះចេះលូតឡើងតាមទឹក បើទឹកឡើងដល់កំពស់ ១០ហត្ថ ក៏ស្រូវលូតឡើងកំពស់នោះដែរ។ នេះប្រហែលជាពូជស្រូវមួយបែបផ្សេងទៀតហើយ។ ស្រែអំពកនិងថ្នាលបន្លែ គេមិនប្រើគ្រឿងស្មោគគ្រោក ដែលជាហេតុនាំអោយមិនស្អាតនោះទេ។ ពួកចិនដែលទៅដល់ស្រុកនោះ ក៏គេមិនហ៊ាននិយាយរឿងពាងលាមកនៅប្រទេសចិនអោយពួកនោះដឹងដែរ ព្រោះខ្លាចគេមើលងាយ។ នៅក្នុងផ្ទះពីរបីខ្នង គេជីករន្ធៅបង្គន់អាច់មួយហើយគេប្រក់ស្បូវ។ ដល់កាលណាពេញទៅនោះ គេលប់ចោលវិញ ហើយទៅជីករន្ធៅមួយទៀត។ ទៅពេលដែលបន្ទោរបង់រួច គេតែងតែចុះទៅលាងអែក្នុងស្រះអោយបានស្អាតជានិច្ច តែគេយកតែដៃឆ្វេងទៅលាងទេ អែដៃស្តាំគេទុកបរិភោគបាយ។ ពួកគេមើលឃើញជនជាតិចិនចូលបង្គន់ហើយយកក្រដាសកិត គេសើចថែមទាំងមិនចង់អោយឡើងលើផ្ទះគេទៀតផង។ ស្រីៗស្រុកនេះ បត់ជើងតូចឈរដូចប្រុសដែរ ជាការគួរអោយអស់សំនើចណាស់។

## ១៨. អំពីទឹកដី

ចាប់តាំងពីចូលក្នុងស្រុក ចេងផ្លូវមក ខ្ញុំមើលឃើញសុទ្ធតែព្រៃឈើវែងអន្លាយ នៅតាមមាត់ទន្លេដ៏ធំធេង មានដើមឈើធំចាស់បុរាណ និង គុម្ពផ្កៅស៊ុបទ្រុបចំងាយរាប់រយលី ហើយមានសំលេងបក្សាបក្សីស្រែទ្រហឹងអឹងកង នៅទីនោះផង។ លុះទៅដល់ពាក់កន្តាលទន្លេ ទើបមើលទៅឃើញវាលស្រែដ៏ធំធេង គ្មានឃើញដើមឈើមួយដើមឡើយ គេមើលទៅឃើញតែស្រូវទុំនៅសព្វទិសទីប៉ុណ្ណោះ។
មានសត្វគោព្រៃរាប់រយរាប់ពាន់ បានមកផ្តុំគ្នាជាហ្វូងនៅទីនោះ។ មានវិស្សីដុះជាប់គ្នាជាដងព្រៃ មានចំងាយរាប់រយលី ហើយវិស្សីទាំងនោះមានជួរបន្លានៅត្រង់គ្រប់ថ្នាំង។ ទំពាំងវិស្សីមានរសជាតិហាងខ្លាំងណាស់ ហើយនិងមានភ្នំនៅគ្រប់ទិសទាំងបួនទៀតផង។

## ១៩. អពីផលានុផល

ស្រុកនេះ មានភ្នំច្រើន និងមានដើមឈើប្លែកៗ។ កន្លែងណាដែលគ្មានដើមឈើទេ គឺជាកន្លែងដែលសត្វរមាសនិងដំរីរស់នៅ។ ពពួកសត្វស្លាបដ៏មានតំលៃ និង សត្វម្រឹគដ៏ប្លែកៗ មានច្រើនអិតគណនា។ មានសត្វចចាតពណ៌ និងរោមល្មិត ភ្លុកដំរី កុយរមាស ឃ្មុំផ្លិតធំៗ ឈើចន្ទន៍ក្រស្នា ក្រវាញ ជ័រចុង បញ្ញើក្អែក (ជីកេង) ប្រេងសំរោង (តែហ្វងជី)។

ចចាតជាសត្វមួយបែប គេកំរចាប់វាបានណាស់។ នៅក្នុងព្រៃមានស្រះ រឺ ត្រពាំង ហើយនៅក្នុងទឹកនោះមានត្រីជាច្រើន។ សត្វចចាត វាហើរចេញពីព្រៃមកចាប់ត្រីនោះជាអាហារ។ ពួកអ្នកព្រៃគេយកស្លឹកឈើបិទបាំងខ្លួនហើយទៅអង្គុយក្បែរមាត់ទឹក។ គេយកមេចចាតផ្ទាក់មួយដាក់ក្នុងទ្រុង ដើម្បីនឹងបញ្ឆោតចាប់យកចចាតឈ្មោល គឺនៅនឹងដៃគេមានកាន់លប់មួយទៀត រង់ចាំកាលណាចចាតឈ្មោលមកជិត គេគ្របលប់នោះយកវា។ គេធ្វើរបៀបនេះក្នុងមួយថ្ងៃទាល់ល្ងាច ជួលកាលចាប់អិតបានសោះក៏មានដែរ។ ភ្លុកដំរី មានតែអ្នកដែលនៅក្នុងរូងភ្នំឆ្ងាយដាច់ស្រយាលពីគេ ទើបរកបាន។ ដំរីមួយស្រុតស្លាប់ទៅ នៅសល់តែភ្លុកមួយគូប៉ុណ្ណោះ។ ដូច្នេះពាក្យដែលគេធ្លាប់និយាយថា សត្វដំរីក្នុងមួយឆ្នាំប្តូរភ្លុកម្តងនោះមិនពិតទេ។ ភ្នុកណាដែលចាក់នឹងច្បូក រឺ លំពែងបានមក គេទុកជាភ្លុកលេខ១ បើភ្លុកណាដែលគេបានដោយឃើញវាស្រុតស្លាប់ខ្លួនវាភ្លាមគេចាត់ជាភ្លុកល្អលេខ២ បើគេរើសបានដោយដំរីស្លាប់យូរឆ្នាំចោលនៅក្នុងរូងភ្នំ គេចាត់ចាធុនអន់ជាងគេ។

ក្រមួនឃ្មុំ គេរកបានពីដើមឈើចាស់ៗ នៅក្នុងភូមិដែលសត្វឃ្មុំមួយប្រភេទមានចង្កេះស្តួចឆ្មារ ដូចសត្វអង្រ្កងវាធ្វើសំបុក។ អ្នកស្រុកដែលទៅយកឃ្មុំ តាមទូកតូចៗ គេអាចដាក់បានពីរបីពាន់ផ្លិត។ ផ្លិតណាដែលធំជាងគេមានទំងន់ដល់ទៅ ៣០-៤០នាឡិ អែផ្លិតណាដែលតូច ក៏មិនតិចជាង១៨ រឺ ១៩នាឡិដែរ។

កុយរមាសណាដែលពណ៌ស ហើយមានផ្កា គេចាត់ទុកជាកុយល្អ ហើយបើខ្មៅវិញគេទុកជាកុយអន់មិនសូវល្អ។

ឈើចន្ទន៍ក្រស្នា ដុះនៅក្នុងព្រៃស្បាត ព្រៃស្ដុក។ អ្នកស្រុកទៅកាប់យកបានមកដោយពីបាកណាស់ ព្រោះឈើដែលមានខ្លឹម។ ឈើនេះមានសាច់ស្រាយកំរាស់៨ រឺ ៩តិក។ ទោះជាដើមតូចក៏មានសាច់ស្រាយ ៩ រឺ ៥តិកដែរ។

ក្រវា ពួកអ្នកព្រៃគេដាំនៅលើភ្នំ។

ជ័រចុង គឺជាជ័រឈើម្យ៉ាងដែលអ្នកស្រុកនេះគេយកកាំបិតទៅចោះឈើសំរក់ជ័រមុនមួយឆ្នាំ ដល់ឆ្នាំបន្ទាប់មក ទើបគេទៅយកជ័រនោះមក។ បញ្ញើជើងកែង (អ័រគីដេ?) ដុះនៅលើមែកឈើមួយប្រភេទ ដូចគ្នានឹងដើមមនដែលដុះផ្ញើនឹងគេដូច្នេះដែរ ហើយគេកំរនឹងរកបានណាស់

ប្រេងសំរោង គេយកមកពីផ្លែឈើដើមធំមួយប្រភេទដែលមានសន្ឋានដូចផ្លែដូងល្អិតមូលៗ។ នៅក្នុងផ្លែនោះមានគ្រាប់ច្រើនទៀត។ អែម្រេច ដុះព័ទ្ធលើដើមផ្ដៅមួយគួ មានពណ៌បៃតងដូលស្មៅ បើនៅខ្ចីពណ៌ក៏ខ្ចី និងរិតតែហិរណាស់ផង។

## ២០. អំពីរបរជំនួញ

អ្នកស្រុកនេះ ពួកស្រីៗប៉ិនជួញដូរណាស់ ហេតុនេះពួកចិនៗ គេរកប្រពន្ធមួយជាមុនសិន ហើយនឹងបានចំនេញច្រើនដោយគេប៉ិនប្រសព្វរកស៊ី។ រាល់ថ្ងៃតែទៅលក់តាំងពីភ្លឺព្រាងៗ ដល់ពេលថ្ងៃត្រង់ទើបឈប់ ហើយពួកនេះគ្មានគ្រែ រឺ ផ្ទះសំរាប់លក់អិវ៉ាន់ទេ គេច្រើនតែក្រាលវត្ថុ ហាក់ដូចជាកន្ទេលផ្ទាល់នឹងដីតំរៀបគ្នា។ ខ្ញុំលឺគេថា មានបង់ឈ្នួលដីជាលុយអោយពួកមន្ត្រីទៀតផង។

ជំនួញតូចតាច គឺគេជួញស្រូវអង្ករ និង របស់ដែលធ្វើមកពីស្រុកចិន។ បន្ទាប់មក មានលក់ដូរកំនាត់សំពត់ផ្សេងៗ។ ជំនួញធំ គឺគេជួញមាសប្រាក់។ តាមធម្មតា ពួកអ្នកព្រៃ តែឃើញពួកចិនទៅដល់ គេគោរពចិនសំបើមណាស់ ទុកដូចជាបានជួបនឹងព្រះ ហើយក្រាបក្បាលគោពទៀតផង។ លុះដល់ពេលថ្មីៗនេះ ទើបមានការបោកប្រាស់ និង មើលងាយចិន ដោយហេតុមកពីមានមនុស្សទៅច្រើនពេក។

## ២១. ទំនិញចិនដែលគេត្រូវការ

អ្នកស្រុកនេះ គ្មានកើតមាសកើតប្រាក់ទេ គេនឹកឃើញតែមាសមកពីស្រុកចិន គឺមាសប្រាក់ជាផលលេខ១ កំនាត់មានពណ៌ទាំងប្រាំជាលេខ២។ បន្ទាប់មកគេត្រូវការសំនរមកពីស្រុកចេងជីវ ថាំងតែស្មាច់មកពីស្រុកអ៊ូជីវ ចូផ្កាពណ៌មកពីស្រុកជូរជីវ និង ទឹកប្រាក់ជាតិហិង្គុល ក្រដាសសរសេរ ស្ពាន់ធ័រ ថ្មដុត ឈើក្រអូប រិសប៉េកជី ក្រលៀនប្រើស សំពត់សរ

សែថ្មែ សំពត់ហ្វាងឆាវ ផ៍ត្រ ឆ្នាំងដែក ថាសស្ពាន់គជ ម្រ័ក្យណ៍ ក្រាសឈើ ម្ជុល ជាដើម។ ក្រៅពីនេះរបស់ដែលធំៗដូច ជាកន្ទេលស្រុកម៉េងជីវ ដែលគេពេញចិត្តបំផុតគឺ មានសញ្ញារូបម្ទេស តែគេមិនងាយនឹងយកទៅបានទេ។

## ២២. អំពីស្មៅ និង ដើមឈើ

មានដើមទទឹម អំពៅ ផ្កាឈូក ក្រអៅឈូក ផ្លែខេម៉ា ចេក ដូចនៅស្រុកចិនដែរ។ គូលែននិងក្រូចឃ្វិចក៏មានរាងពៅដូច តែជូរ។ ក្រៅពីនេះមានផ្លែឈើព្រៃជាច្រើនដែលប្រទេសចិនយើងមិនធ្លាប់ដែលឃើញ ហើយប្លែកៗទៀតផង។ មាន ផ្កាជាច្រើនដែលល្អៗ ហើយមានក្លិនក្រអូបណាស់។ ផ្កាដែលដុះនៅក្នុងទឹកក៏មានច្រើនយ៉ាង តែខ្ញុំមិនស្គាល់ថាជាឈ្មោះ ផ្កាអ្វីទេ។ ចំនែកដើមថោ លី ហេងបួយ សុង ប៉េក សាំ ក្វាយ ឡី ចោ អ៊ាងលីវ គុយឡាង កេកលួយ ឈើប្រភេទអស់នេះ គ្មានទេ។ នៅស្រុកនោះ ខែទី១ ក៏មានផ្កាឈូកដែរ។

## ២៣. អំពីសត្វស្លាប

បន្ទាសត្វស្លាប ឃើញមានក្ងោក ចចាត លលក ដែលប្រទេសចិនគ្មាន។ ក្រៅពីនេះដូចជាខ្លែង ក្អែក ត្មាត សេក ចាបស្រុក ត្រដក់ កុក ប្រវឹក និងចាបពួកជាដើម សុទ្ធតែមានទាំងអស់។ សត្វស្លាបដែលស្រុកនេះគ្មាន ដូចជា ហ៊ឺងតូវ (ល្វាចេក?) ហុងអេង(ក្ងានព្រៃ) អ៉ឹងអេង (ក្លែងលឿង) តូវអ៊្វ (ត្រចៀកកាំ)..។

## ២៤. អំពីសត្វជើងបួន

សត្វចតុបាទមានរមាស ដំរី គោព្រៃ ដែលប្រទេសចិនគ្មាន។ ក្រៅពីនេះ ខ្លាធំ ខ្លាត្រី ខ្លាឃ្មុំ ជ្រូកព្រៃ ប្រើស ក្តាន់ និង កញ្ជ្រោងជាដើម សុទ្ធតែមានច្រើនណាស់។ សត្វដែលស្រុកនេះគ្មានគឺតោស៊ីងស៊ីង(១) និង អូដ្ឋ។ មាន់ ទា គោ សេះ ជ្រូកនិង ពពែមានច្រើនក្រៃលែង។ តែសេះស្រុកនេះទាបៗណាស់ គោតូចៗក៏មានច្រើនណាស់ដែរ។ សត្វគោនៅរស់ គេ ហ៊ានជិះ តែដល់វាស្លាប់ទៅគេមិនហ៊ានស៊ី និង មិនហ៊ានយកស្បែកវាទេ គេទុកអោយវារលួយទៅតាមចិត្តចុះ ពីព្រោះ វាធ្លាប់ជួយដល់កំលាំងមនុស្សលោក។ វាធ្លាប់តែអូសរទេះ។ ពីដើមមក មិនធ្លាប់មានក្ងានទេ ប៉ុន្តែអិលូវមានហើយ ព្រោះមាននាវាចិនទៅញយៗ គេយកពូជពីស្រុកចិនទៅ។ កន្តុរស្រុកនេះធំៗដុចសត្វឆ្មា ហើយមានកន្តុរមួយមុខទៀត មានក្បាលប្លែកពិសេសធំ ដូចជាក្បាលកូនឆ្កែ។

១ = គឺជាស្វាមាឌធំប៉ុនមនុស្ស ដូចគេធ្លាប់ហៅតាមកុនថា ស្វាគីងកុង

# ៤ - ប្រពៃណីអ្នកស្រុកចេនលា

## ២៥. អំពីបន្លែបង្ការ

បន្លែមាន ត្រកួន ស្ពៃ គូឆាយ ត្រប់ អូរលឹក ត្រលាច ត្រសក់ ឃិញឆាយ។ បន្លែដែលគ្មាននោះគឺ ឆាយថៅ ស្ពៃខៀវ ខូវចេង ប៉ោលេង ជាដើម។បន្លែដូចជាត្រប់ អូរលឹក ត្រសក់ ត្រលាចជាដើម តែដល់ខែទីមួយមានហើយ។ ដើមត្រប់មានដុះរាប់ឆ្នាំមិនទាន់រំលើងចោលក៏មាន។ ដើមគរខ្ពស់ៗជាងផ្ទះទៅទៀត អាយុជាង១០ឆ្នាំមិនទាន់កាប់ចោលក៏មានដែរ។ មានបន្លែច្រើនមុខទៀត ដែលខ្ញុំមិនស្គាល់ឈ្មោះ អែបន្លែដុះក្នុងទឹកក៏មានច្រើនមុខណាស់ដែរ។

## ២៦. អំពីត្រី និង សត្វលូន

ពួកត្រី និង អន្ទើកមាន : ត្រីរ៉ស់ច្រើនណាស់ ក្រៅពីនេះដូចជាត្រឆ្អិន និង ត្រល្អិតអែទៀត រិតតែច្រើនណាស់ទៅទៀត មានត្រីថ្ងរពួដែលធំនាះ មានទំងន់ដល់ជាងពីរនាឡិ ហើយត្រីដែលខ្ញុំមិនស្គាល់ឈ្មោះនោះ ក៏មានច្រើនណាស់ដែរ ដែលជាត្រីមកពីសមុទ្រទឹកសាប (ទន្លេសាប)។ ចំនែកត្រីទឹកប្រៃវិញ ក៏មានច្រើនមុខ រាងដូចអន្ទង់ និង ត្រីខ្ជឹងបឹងដែរ។ ពួកអ្នកស្រុកនេះមិនស៊ីកង្កែបទេ ម្ល៉ោះហើយដល់ពេលយប់ គេឃើញកង្កែបលោតច្រវាត់កាត់ផ្លូវដើរ។ អន្ទើក កន្ធាយធំៗប៉ុនចង្កេះអុំ។ នោះជាអន្ទើក មានអាយុដល់ទៅ៦ឆ្នាំ ក៏គេនៅតែស៊ីវាដែរ។ បង្កងនៅស្រុកឆាណា(កំពុងឆ្នាំង) មួយមានទំងន់ដល់ជាងមួយនាលិ។ ជើងអន្ទើកនៅស្រុកចេនភូមានប្រវែងជាង ៨ - ៩តឹក។ ក្រពើធំៗប៉ុនទូក។ មាននាគជើងបួនមួយប្រភេទយ៉ាងចំលែក អិតមានស្នែងទេ។ ចំពុះទា លៀស ខ្យង ខ្ចៅ នៅក្នុងសមុទ្រទឹកសាប (ទន្លេសាប) នោះគ្រាន់តែលូកដៃទៅក៏យកបានភ្លាម តែខ្ញុំមិនឃើញមានក្តាមទេ ខ្ញុំស្មានថាប្រហែលជាមានដែរ តែគេមិនស៊ីទេមើលទៅ(១)។

១ = ការពិតស្រុកយើងមានក្តាមច្រើនណាស់ពីដើមមក តែប្រហែលជាលោកជីវតាក្វាន់ មិនប្រទះឃើញក្នុងទន្លេ។

## ២៧. អពីការបិទស្រា

ស្រាស្រុកនេះមានបួនយ៉ាង ស្រាលេខមួយ ចិនហៅស្រាទឹកឃ្មុំ ដេលគេយកជាតិថ្នាំ និង ទឹកឃ្មុំលាយជាមួយទឹក ហើយផ្សំធ្វើឡើង។ បន្ទាប់មកហៅតាមពាក្យអ្នកស្រុកថា ផេងកេស៊ី ដែលគេយកស្លឹកឈើមកផ្សំ គឺស្លឹកឈើឈ្មោះផេងកេស៊ីនេះអែង ជាឈើ១ប្រភេទ។ បន្ទាប់មកទៀត គេយកអង្ករ រឺ បាយដែលសេសសល់ទៅបិទស្រា ហៅប៉ាវលេងកាក ព្រោះពាក្យថា ប៉ាវលេងកាក បានន័យថាអង្ករ(២) ក្រៅពីនេះទៀត មានស្រាទឹកស្លៃស្ករ ដែលគេយកជាតិស្ករមកបិទអោយកើតទៅជាស្រា។ បើគេចូលទៅស្រុកភូមិតាមមាត់ទន្លេ គេប្រទះស្រាមួយមុខទៀតធ្វើពីទឹកក្រចាប់ ព្រោះក្រចាប់ដុះនៅមាត់ព្រែក ហើយស្លឹកវាមានរសជាតិស្ករ ដែលគេអាចយកមកធ្វើជាស្រាបាន។

២ = អង្ករពីដើម គេហៅ រង្ករ។

## ២៨. អំបិល ទឹកខ្មេះ ស៊ីអ៊ីវ និង មី

នៅប្រទេសនេះ ការធ្វើរបស់អស់ទាំងនេះ អិតមានហាមឃាត់ទេ។ តាមឆ្នេរសមុទ្រចាប់ពីចេនភូ និង ប៉ាំងកាង(១) គេធ្វើអំបិលដោយទឹកសមុទ្រ។ នៅក្នុងភ្នំមានរ៉ែ ដែលគេបានជាតិថ្ម ធ្វើពីអំបិលប្រសើរជាងអំបិលសមុទ្រទៀត និងយកថ្មធ្វើជាវត្ថុដទៃៗទៀត។ ពួកអ្នកស្រុកនេះមិនចេះធ្វើទឹកខ្មេះទេ តែគេចូលចិត្តប្រើជាតិជូរនៅម្ជូបណាស់ គេត្រាំទឹកកាំផេង(២) ធ្វើជាម្ជូរ កាលណាដើមឈើនេះកំពុងតែលាស់គេយកស្លឹករីទងខ្ចី កាលណាមានផ្លែគេយកផ្លែវិញ។

គេមិនចេះធ្វើមីទេ ព្រោះតែគ្មានស្រូវសាលី និង សន្តែក។ ពួកនេះក៏មិនចេះធ្វើដំបែគ្រាប់ដែរ កាលណាគេបិទស្រាគេលាយទឹកឃ្មុំ និងទឹកត្រាំស្លឹកឈើ អោយបានជាក្បាលស្រា ហើយក្បាលស្រានេះ ដូចគ្នានឹងស្រាស នៅក្នុងភូមិស្រុកយើងដែរ។

១ = ចេនភូ = ចន្ទបូរ រី ចន្ទបុរី ។ ប៉ាំកាង = បាកាន ។ ២ = តាមមើលទៅ ដើមនេះគួរជាដើមអំពិល ព្រោះគេប្រើស្លឹកក៏បានផ្លែក៏បាន។

## ២៩. អំពីដង្កូវនាង និង ដើមមន

អ្នកស្រុកនេះមិនចេះចិញ្ចឹមដង្កូវនាងទេ ទាំងដើមមនក៏គ្មានដាំដែរ។ ស្រីៗមិនចេះប៉ាក់ជុលនិងដេរប៉ះឡើយ។ គេចេះត្បាញសំពត់ តែមិនចេះរវៃអំបោះទេ គេយកដៃត្រកួញសរសៃកប្បាស អោយកើតជាអំបោះ ហើយគេយកមកត្បាញ មិនបាច់កីទេ។ គេចងសរសៃអំបោះម្ខាងជាប់នឹងចង្កេះគេ ហើយគេត្បាញចុងម្ខាងទៀត ដោយមានត្រល់ជាបំពង់ឫស្សី។ ប៉ុន្មានឆ្នាំក្រោយមកនេះ មានពួកសៀមចូលមកនៅ គេក៏ដាំមន ចញ្ចឹមនាងធ្វើសូត្រ ដោយយកពូជមកពីស្រុកសៀម។ នៅស្រុកនេះ គ្មានដើមធ្មៃទេ មានតែដើមក្រចៅ។ ជនជាតិសៀមចេះដេរប៉ាក់ចំនាប់ បើសំពត់អ្នកស្រុកនេះរហែក គេយកមកពឹងស្រីសៀមអោយដេរប៉ះអោយ។

## ៣០. អំពីប្រដាប់ប្រើប្រាស់

អ្នកស្រុកធម្មតា មានផ្ទះនៅហើយ តែគ្មានតុកៅអី ចានដែក រឺ ថាំងជាដើមប្រើទេ គេប្រើឆ្នាំងដីសំរាប់ដន្តាំបាយ ហើយឆ្នាំងមួយទៀតសំរាប់ស្ល។ គេយកថ្មបីដុំកំកល់ធ្វើជាជើងក្រាន និងយកត្រលោកដូងធ្វើជាវែក។ គេប្រើចានទាបមកពីស្រុកចិនសំរាប់ដាក់បាយ អែសំល គេដាក់នឹងកន្ទោងស្លឹកឈើដែលគេខ្ទាស់មិនលេចទឹកទេ។ គេយកស្លឹកក្រចាប់ធ្វើជាស្លាបព្រាដួសសំលបញ្ចូលមាត់ កាលណាប្រើរួចគេបោះចោលទៅ។ ម្ហូបថ្វាយព្រះ ថ្វាយទេវតា ក៏គេដាក់នឹងស្លឹកដូ

ច្នេះដែរ។ គេយកគ្រឿងដែលធ្វើពីស្ពាន់ស ដែលដាក់ទឹកនៅក្បែរខ្លួន សំរាប់ជ្រលក់ដៃកុំអោយជាប់បាយនឹងដៃ ព្រោះគេបរិភោគដោយផ្ទាល់នឹងដៃ បើគ្មានទឹកជ្រើមដៃមិនបានឡើយ។ គេប្រើផ្តិលសំរិទ្ធសំរាប់ចាក់ស្រាផឹក ចំនែកអ្នកក្រប្រើផ្តិលដែលធ្វើអំពីដី រីអែពួកមន្ត្រី គេប្រើផ្តិលធ្វើពីប្រាក់ រីជាមាសផងក៏មាន។ បើក្នុងអោកាសបុណ្យធំៗ ដូចជាបុណ្យជាតិវិញ គេប្រើប្រដាប់ទាំងនេះ ធ្វើសុទ្ធតែពីមាសទាំងអស់ ហើយមានរបៀបផ្សេងពិសេសទៀតផង។ នៅនឹងដី គេក្រាលកន្ទេលមកពីស្រុកម៉េងជីវ (ស្រុកចិន) រី មួយក្រាលស្បែកខ្លាធំ ខ្លារខិន ស្បែកប្រើស រមាំង ពុំនោះទេ គេប្រើកន្ទេលផ្តៅ។ នៅពេលជិតៗនេះ គេទើបនឹងចេះប្រើតុទាបៗ មានកំពស់ប្រហែលមួយហត្ថ។ សំរាប់កន្លែងគេដេក គេប្រើកន្ទេលរិស្សី តែអិលូវនេះមានខ្លះប្រើគ្រែទាបៗខ្លះដែរហើយ ដែលជាគ្រែធ្វើមកពីស្រុកចិន។ ម្ហូបចំនី គេគ្របដោយសំពត់ អែនៅក្នុងវាំង គេប្រើសំពត់ព្រែប៉ាក់ខិន រី ខ្សែសយ ដែលបានមកពីពួកឈ្មួញសំពៅប្រទេសក្រៅនាំយកមកថ្វាយ។ ដើម្បីស្រិតអង្ករ គេមិនប្រើត្បាល់កិនទេ គេប្រើត្បាល់បុកទៅវិញ។

## ៣១. អំពីរទេះ និង អង្រឹងស្នែង

ការធ្វើអង្រឹងស្នែង គេយកឈើមួយដើមដែលកោងចំកន្តាល អ៊ែនចុះក្រោម ចុងសងខាងងឡើងលើ ហើយនៅចុងនោះគេឆ្លាក់ជាក្បាច់ផ្កាភ្ញី និង មានស្រោបមាស រី ប្រាក់ពីក្រៅឈើនោះផង គេហៅថា អង្រឹងដងមាស រី ដងប្រាក់ សំរាប់តាមលំដាប់ថ្នាក់។ ចំងាយពីចុងដងប្រហែលមួយហត្ថ គេវាយដែកធ្វើចាស្រយូវម្ខាងមួយ ហើយគេយកសំពត់មួយផ្ទាំងយ៉ាងធំ ហើយក្រាស់ មកបត់ធ្វើជាត្រចៀកសំរាប់ស៊កខ្សែភ្ជាប់ទៅ នឹងស្រយូវដែកនោះ។ អ្នកជិះគេអង្គុយលើសំពត់នោះ ដៃកាន់ជាយសំពត់ផង ហើយអោយមនុស្សពីរនាក់ជានាក់សែង។ នៅក្បែរអង្រឹងស្នែង តែងតែមានប្រដាប់មួយទៀត មានសន្ទានដូចដំបូលទូកតែធំជាង ក៏មានបិទបាំងដោយសំពត់ព្រែប្រាំពណ៌ ហើយដោយមានមនុស្សបួននាក់សែង និងមានមនុស្សដើរតាមហែពីក្រោយផង។ បើធ្វើដំនើរទៅឆ្ងាយ គេអាយជិះដំរីនិងសេះ ព្រមទាំងប្រើរទេះដែរ។ រទេះនៅស្រុកនេះ ក៏មានលក្ខណដូចរទេះស្រុកអែទៀតដែរ តែគេជិះសេះអិតមានកែបទេ អែដំរីក៏គ្មានប្រដាប់សំរាប់អង្គុយដែរ។

## ៣២. អំពីទូកច្រវា

អំពីទូកធំៗ សុទ្ធតែធ្វើឡើងដោយយកឈើរឹងៗ មកចាំងជាបន្ទះក្តារសិន រួចទើបវាយផ្តុំឡើងជាទូក។ មេជាងអិតមានប្រើនរណាទេ គេប្រើតែដឹង ហើយនិងដែកខួង ដែលជាហេតុនាំអោយខាតឈើនិងកំលាំងច្រើនណាស់។ នៅពេលដែលគេចង់កាត់ឈើជាកំនាត់ គេតែងយកដែកខួងមកខួងទំលុះផ្តាច់តែម្តង ទោះជាធ្វើផ្ទះក៏ធ្វើរបៀបគ្នានេះដែរ។ គេមាន

ប្រើដែកគោលវាយធ្វើទូកដែរ។ គេយកស្លឹកលេង (ក្រចាប់) មកប្រក់ធ្វើដំបូល ដោយយកដើមស្លាមកពុះជាបន្ទះគាបសង្កត់ស្លឹកនោះផង។ ទូករបៀបនេះ គេហៅថា «ស៊ីនណា»។ គេបិទពរទូកដោយជ័រឈើ ខ្លាញ់ត្រី លាយនឹងកំបោរ។ ចំនែកទូកតូចវិញ គេលុងធ្វើពីឈើមួយដើមធំ។ គេយកភ្លើងដុតពេលអោយទន់សាច់ឈើ ទើបទល់បំប៉ោងពង្រីកពោះទូកអោយធំ ក្បាលកន្សៃស្រួច អិតមានប្រើដំបូលទេ តែដាក់បានមនុស្សច្រើននាក់ណាស់ដែរ។ ទូករបៀបនេះ ហៅថា កុយលាំង។

## ៣៣. អំពីខេត្ត

ខេត្តមានទាំងអស់ជាង ៩០ គឺខេត្ត ចេងពូ (ចន្ទបូរ) ឆាណា(ឆ្នាំង) ប៉ាកាង(បានកាន) មុងលាង ប៉ូចស៊ី ភូវមួយ ទីហ្វង បាក់លុតប៉ោ ណៃកាខាំង ប៉ូចស៊ីលី ជាដើម។ ក្រៅពីនេះ ខ្ញុំមិនចាំឈ្មោះទេ។ ខេត្តនិមួយៗ សុទ្ធតែមានមន្ត្រីកាន់កាប់ ហើយមានធ្វើបន្ទាយឈើជារបាំងផង។

## ៣៤. អំពីស្រុកភូមិ

នៅក្នុងភូមិនិមួយៗ ជួនមានវត្ត ជួនមានប្រាសាទ ហើយមានមន្ត្រីម្នាក់នៅត្រួតត្រាយ៉ាងហ្មត់ចត់។ មន្ត្រីនោះគេហៅថា មួយស៊ី។ នៅតាមផ្លូវធំៗ តែងមានសាលាមួយសំរាប់ឈប់សំរាក គេហៅថាសិមប៉ាក់។ ប៉ុន្តែនៅពេលថ្មីៗនេះ មានកើតចំបាំងជាមួយនឹងប្រទេសសៀម ភូមិទាំងនេះក៏ប្រែក្លាយទៅជាដីវាលទៅវិញ។

## ៣៥. អំពីប្រមាត់ប្រមង់

កាលពីមុននេះ តែដល់ខែទី៨ គេតែងធ្វើការចាប់មនុស្សយកប្រមាត់ ពីព្រោះស្តេចចាម ក្នុងមួយឆ្នាំគេសុំយកប្រមាត់មួយថូ ដែលមានចំនួនរាប់ពាន់។ នៅក្នុងពេលយប់ គេចាត់ពួកអ្នកយកប្រមាត់ (ប្រមាត់ប្រមង់?) ដើរទៅតាមផ្លូវនានាក្នុងទីក្រុង និង ក្នុងភូមិ។ បើប្រទះមនុស្សណាដើរក្នុងពេលយប់ស្ងាត់នោះ គេចាប់យកខ្សែចងក្បាលអោយជាប់ ហើយកូនកាំបិទចាក់ក្រោមឃ្លៀកខាងស្តាំខ្វះយកប្រមាត់ដាក់ក្នុងថូ លុះត្រាតែបានពេញចំនួន ទើបគេយកទៅថ្វាយស្តេចក្រុងចាម។ ប៉ុន្តែគេមិនយកប្រមាត់ជនជាតិចិនទេ ពីព្រោះមានកាលមួយឆ្នាំនោះ គេយកប្រមាត់របស់ចិនមួយទៅលាយនឹងគេក៏បន្តាលអោយស្អុយរលួយខូចប្រមាត់នៅក្នុងថូ លែងប្រើការបានទាំងអស់ ពេលក្រោយមក គេលែងមាការដើរចាប់យកប្រមាត់ទៀតហើយ ហើយគេចាត់មន្ត្រីដោយលែកសំរាប់មុខងារខាងយកប្រមាត់ពីពួកក្រោមអំនាចខ្លួន ដែលតាំងអោយនៅជាយក្រុងក្បែរទ្វារខាងជើង។

## ៣៦. អំពីរឿងចំលែក

នៅក្នុងកំពែងនាទិសខាងកើត មានអ្នកព្រៃម្នាក់នោះរួមរ័កជាមួយប្អូនស្រីអែងបង្កើត ក៏ស្រាប់តែជាប់ស្បែកសាច់គ្នាបេះមិនចេញរហូតគ្រប់បីថ្ងៃ អិតមានស៊ីចុកអ្វីសោះ ក៏ស្លាប់បង់ជីវិតទៅ។ អ្នកស្រុកខ្ញុំម្នាក់សែ «ស៊ី» គេបានរស់នៅស្រុកនេះរវាងសាមសិបប្រាំឆ្នាំ គេថា គេបានឃើញរឿងនេះច្បាស់ពិតពីលើក ហើយគេថា បានជាសក្តិសិទ្ធដូច្នេះ ព្រោះបារមីព្រះរបស់ស្រុកនេះខ្លាំងពូកែណាស់។

## ៣៧. អំពីការងូតទឹក

ប្រទេសនេះក្តៅខ្លាំងណាស់ ក្នុងមួយថ្ងៃៗ បើមិនងូតទឹកច្រើនលើកទេ គឺច្បាស់ជាអត់ទ្រាំមិនបានឡើយ ទោះបីនៅពេលយប់ក៏ជៀសមិនរួចពីការងូតទឹកម្តង រឺ ពីដងដែរ។ គេគ្មានបន្ទប់ទឹក គ្មានចានដែក គ្មានប៉ោតទេ។ ក្នុងផ្ទះមួយតោងមានស្រះមួយ បើពុំនោះទេ គេព្រួតគ្នា២ -៣ផ្ទះទៅងូតទឹកស្រះមួយដោយលែងខ្លួនចោល អិតគិតពីរឿងខ្មាសគ្នាស្រីប្រុសទេ ។ ប៉ុន្តែបើអូវពុកម្តាយចាស់ គាត់ទៅដល់ស្រះមុន ក្មេងស្រីប្រុសមិនហ៊ានទៅជិតទេ ប្រសិនបើក្មេងកំពុងតែងូតទឹកស្រះនោះមុនវិញ ក៏ចាស់ទុំនោះ នាំគ្នាគេចចេញដែរ។ មនុស្សមានវ័យស្របាលគ្នា អិតគិតអៀនខ្មាសគ្នាឡើយ។ គេយកតែដៃឆ្វេងបិទបាំងកេរ្តខ្មាសរបស់ខ្លួន ហើយដើរចុះក្នុងទឹកទៅ។ ជួនកាលក្នុងរយៈ ៣.៤ថ្ងៃ រឺ ៥-៦ថ្ងៃម្តង ពួកស្រីៗទីក្រុងមួយក្រុម មានគ្នា ៣-៥នាក់ នាំគ្នាចេញទៅមុជទឹកទន្លេខាងក្រៅកំពែងក្រុង។ នៅពេលដែលទៅដល់ទន្លេនោះ គេដោះសំពត់ដេលរ័ណ្ឋខ្លួនចេញ ដើរចុះទៅក្នុងទឹក ហើយទៅជួបជុំគ្នានៅក្នុងទន្លេនោះរាប់ពាន់នាក់។ សូម្បីតែពួកស្រីៗដែលមានត្រកូលខ្ពង់ខ្ពស់ ក៏ដូច្នេះដែរ។ គេអិតមានខ្មាសអ្វីទេ ចាប់តាំងពីក្បាលដល់ចុងជើង មើលគ្នាឃើញទាំងអស់។

នៅមាត់ទន្លេក្រៅទីក្រុងនោះ រាស់ថ្ងៃតែងតែមានជនជាតិចិននៅទំនេរ ហើយលួចនាំគ្នាទៅចាំមើលលេងតាមគំនិតខិលខូច ហើយលឺថា គេឆ្លៀតពេលនៅក្នុងទឹកនោះផង។ ទឹកនោះនៅក្តៅអុនៗជានិច្ច លុះត្រាដល់ពេលយប់យាមបួនទើបត្រជាក់ លុះដល់ព្រឹក ថ្ងៃរះឡើងក៏ក្តៅអុនៗឡើងវិញទៀត។

## ៣៨. ការចូលជ្រកនៅ (អន្តោប្រវេសន៍)

ពួកជនជាតិចិន ដែលជាអ្នកឈ្នួញដើរសំពៅ កាលមកដល់ស្រុកនេះក៏ពេញចិត្តគេខ្លាំងណាស់ ព្រោះស្រុកនេះមិនបាច់ប្រើសំលៀកបំពាក់ច្រើន ហើយអង្ករគេក៏ស្រួលរក ប្រពន្ធក៏ស្រួលរកបាន អែផ្ទះសំបែងក៏ងាយធ្វើ គ្រឿងប្រើប្រាស់ក៏ងាយរក ការលក់ដូរក៏ធូរងាយ ម្លោះហើយបានជាមានអ្នកចូលពីស្រុកក្រៅ មករស់នៅស្រុកនេះច្រើនណាស់។

## ៣៩. អំពីកងទ័ព

កងទ័ពធ្វើដំនើរដោយលែងខ្លួនអិតអាវ។ ដៃស្តាំគេកាន់លំពែង ដៃឆ្វេងកាន់ខែល គ្មានប្រើធ្នូនិងព្រួញទេ កាំភ្លើងធំ រី អាវក្រោះក៏គ្មានដែរ។ តាមលឺគេថា កាលកើតចំបាំង នឹងជាតិសៀម គេនាំគ្នាកេណ្ឌអ្នកស្រុកទៅវាយដោយកំលាំងតែម្តង ពុំមានប្រើល្បិចកលអុបាយអ្វីឡើយ(១)។

១ = រឿងនេះ មកពីជីវតាក្វាន់ មិនបានឃើញ នឹងស៊ើបពត៌មានទេ ព្រោះតាមអែកសារជាច្រើនណាស់ ថាខ្មែរចេះរៀបចំទ័ពត្រឹមត្រូវ មានសាស្ត្រាវុធ និងក្បួនយុទ្ធសាស្រ្តផង។

## ៤០. អំពីការយាងចេញនៃមហាក្សត្រ

ខ្ញុំបានលឺគេនិយាយថា ស្តេចអង្គមុនៗ មិនដែលយាងចេញទៅណាទេ ព្រោះខ្លាចមានរឿងហេតុ។ ស្តេចអង្គថ្មីនេះត្រូវសនិសាស្តេចមុន(២)។ កាលពីដើម លោកមានឋានៈជាមេទ័ព។ បិតាក្មេកនោះសព្វព្រះទ័យ នឹង បុត្រីព្រះអង្គណាស់បានជាកូនស្រីនេះ លួចយកព្រះខ័នមាសបាន ហើយយកទៅអោយប្តីរបស់ព្រះនាង។ បុត្រាបង្កើតក៏មិនបានទទួលរាជស្នងបិតា ក៏លើកគ្នាទៅដន្តើមរាជ តែត្រូវស្តេចថ្មីជ្រាបការទាន់ ចាប់បាននាំយកមកកាត់ម្រាមជើង ហើយយកទៅដាក់គុកងងឹត។ ស្តេចថ្មីនេះមានពាក់អាវក្រោះដែក ទោះបីគេប្រើកាំបិត រីព្រួញក៏មិនអាចមុតបានដែរ។ ដូច្នេះហើយ ទើបព្រះអង្គហ៊ានយាងចេញក្រៅ។ ខ្ញុំបានទៅនៅទីនោះជាងមួយឆ្នាំ បានឃើញព្រះអង្គយាងចេញមក៤-៥ដង។ ការយាងចេញមកម្តងណាតែងមានទ័ពទៅការពារពីខាងមុខ មានអ្នកកាន់ទង់ជ័យ និង មានតន្រ្តីនៅខាងក្រោយ។ ស្រីស្នំ៤-៥នាក់ស្លៀកសំពត់ផ្កាសៀតផ្កានៅសក់ក្បាល ដៃកាន់ទៀនធំ ដើរជាក្រុមៗ។ ទោះបីនៅពេលថ្ងៃភ្លឺក្រលែតក្តី ក៏គេអុជទៀនដែរ។ នៅក្នុងចំនោមស្រីស្នំទាំងនោះ មានខ្លះកាន់គ្រឿង មានដូចជាភាជន៍មាស និងគ្រឿងបិទបាំងជាដើមផ្សេងៗពីគ្នា មិនដឹងជាគេយកទៅប្រើការអ្វីខ្លះឡើយ។ នៅមានស្រីស្នំខ្លះទៀត កាន់ស្នរ លំពែង ខែល ជាទ័ព នៅខាងក្នុងមួយក្រុមទៀតផង មានរទេះទឹមពពែ និង រទេះទឹមសេះ ដែលមានតាក់តែងដោយគ្រឿងមាសបរដង្ហែដែរ។

២ = ស្តេចអង្គនេះ លោក A-Leclère សរសេរក្នុង Histoire du Cambodge ថា : ក្នុងចន្លោះពេលនោះ មានស្តេចសោយរាជជាច្រើនអង្គមិនប្រាកដនាម តែគេសំគាល់បានមួយតាមលិលាចារឹក គឺ ស្តេចជយបរមេស្វរៈ (ព្រះបាទអិន្ទ្រវរ្ម័នទី៣) ដែលសោយរាជក្នុងចន្លោះឆ្នាំ ១២៥០ - ១៣០០នេះ។

ពួកនាម៉ឺនសព្វមុខមន្ត្រី និង ពួកញាតិវង្ស សុទ្ធតែជិះដំរី នៅខាងមុខ បើមើលពីចំងាយទៅឃើញសុទ្ធតែក្លស់ពណ៌ក្រហមអិតគណនា។ បន្ទាប់មកទើបដល់ព្រះមហេសីធំតូច តាមលំដាប់ថ្នាក់ ជិះអង្រឹងស្នែងជិះរទេះសេះ រី ជិះដំរីដ៏មានក្លស់

បើកបាំងមិនតិចជាងមួយរយទេ។ បន្ទាប់ទៀត ទើបដល់ព្រះរាជាព្រះទ្រង់ឈរនៅលើខ្នងដំរី ព្រះហស្តកាន់ព្រះខ័នទិព្វ។ ភ្លុកដំរី ព្រះទីនាំងសឹងមានពាក់ចង្កំមាស។ មានក្លស់ស (ស្វេតច្ឆត្រ) ចំនួន២០ ដ៏មានសែមមាសបើកបាំងជុំព្រះអង្គដែលសុទ្ធតែជាក្លស់ដងមាស នៅជុំវិញព្រះអង្គមានទ័ពដំរីប្រដាប់ដោយអាវុធជាគ្រឿងការពារ។ បើប្រសិនជាស្តេចយាងទៅណាជិតៗទេ ទ្រង់គង់លើគ្រែស្នែង (ព្រះវរ) ហើយអ្នកសែងសុទ្ធតែស្រីៗស្នំ។ សឹងតែរាល់ដង កាលណាស្តេចយាងចេញដំនើរតែងមានរូបស្តូបតូចមួយ ហើយពីមុខនេះមានព្រះពុទ្ធរូបមាសមួយអង្គផង សែងពីមុខព្រះរាជា។ បន្តាជនដែលនៅតាមដងផ្លូវ ត្រូវសំពះលុងជង្គង់ក្រាបក្បាលដល់ដីដែលគេហៅថា សំប៉ា (សំពះ?) បើពុំដូច្នោះទេ នឹងត្រូវគេចោទថា មើលងាយព្រះចេស្តា ហើយនឹងត្រូវគេចាប់យកទៅឃុំចោល អិតដោះលែងឡើយ។

ក្នុងមួយថ្ងៃព្រះរាជាទ្រង់កិច្ចការរដ្ឋពីរលើក គឺទទួលសវនាការពីរដ្ឋមន្ត្រី និង រាស្ត្រ ប៉ុន្តែគ្មានបញ្ជីកត់កំនត់ចំនួន មនុស្សនឹងកិច្ចការនោះទេ។ បើមន្ត្រី រឺ រាស្ត្រណាចង់ចូលគាល់ ត្រូវតែចូលទៅអង្គុយបត់ជើងផ្ទាល់នឹងដីរង់ចាំជាមុន។ មួយសន្ទុះក្រោយមក ទើបគេលឺសូរសំលេងតន្ត្រីរងំខាងក្នុង។ អ្នកនៅខាងក្រៅផ្លុំស័ង្ខតបទៅវិញ។ ខ្ញុំលឺគេថា គេប្រើតែទីនាំងគ្រែ ស្នែងមាស (ព្រះវរមាស) ទេ បើគ្រាន់តែយាងជិតៗ។ បន្ទាប់មកគេឃើញស្រីស្នំពីរនាក់រូតវាំងននពញរះវរនោះឡើង ក៏លេចឃើញស្តេចគង់ឈរកាន់ព្រះខាន់ នៅក្នុងស៊ុមមាសជាទីព្រះទែនគង់ប្រថាប់។ ពេលនោះ ទាំងមន្ត្រីទាំងរាស្ត្រសុទ្ធតែអោនក្បាលលើដៃសំពះ លុះត្រាតែផុតសំលេងស័ង្ខដែលជាសញ្ញាអោយងើបមុខឡើង ទើបហ៊ានងើបព្រមគ្នា។ ដែលជាកេរ្តដំនមកច្រើនស្តេចហើយ។ លុះទ្រង់ប្រស្រ័យការចប់ហើយ ស្តេចយាងចូលវិញ ដោយមានស្រីស្នំពីរនាក់រូតរនាំងបិទដូចដើម អ្នកទាំងអស់គ្នាក៏ក្រោកឈរហើយអែបៗខ្លួនទៅកៀនរៀងខ្លួនទៅ។ ពិតមែនតែស្រុកនេះ មិនសូវស៊ីវិល័យ តែគេស្គាល់ច្បាប់ទំលាប់គោរពព្រះមហាក្សត្រ។

# ពន្យល់ពាក្យខ្លះ

## ជាសំដីខ្មែរ ហើយ ជីវតាក្វាន់ កត់ជាអក្សរចិន (រៀបតាមលំដាប់អក្សរ)

**កាងពាងឈ្វ រឺ កាងពាងជូ :** តាមយោបល់របស់លោក ប៉េលិយោតថា ពាក្យកាងពាង ក្លាយពីពាក្យកំពង់ ។ តាមយោបល់របស់យើងថា កំពង់ចិន សរសេរតែមួយមាត់ទេថា ប៉ុង ដូចជាប៉ុងចាំ : កំពង់ចាម។ ម្យ៉ាងទៀត ឈ្វ វៃ ជូ ប្រែមិនកើត ។ ដូច្នេះ យើងយល់ថាពាក្យនេះទំនងជាមកពីពាក្យ កំពែងជួរ ទៅវិញ ព្រោះពីដើមទីក្រុងនិមួយៗ តែងធ្វើជាកំពែងជាជួរព័ទ្ធជុំវិញ ជាព្រំដែននៃទីក្រុង។ ក្នុងបរិវេណនៃកំពែងនេះ អ្នកក្នុងរស់នៅ មានវាំង មានផ្សារផ្សោ មានផ្ទះអ្នកទីក្រុង។ ទំលាប់បុរាណហៅថាកំពែង រឺ សីមា។ សូមមើលពាក្យលោក សុត្តន្តប្រីជាអិន្ទ ក្នុងគតិលោកទី១ និយាយហៅទីក្រុងថាកំពែង។ នៅសិលាចារឹកជាច្រើនក៏ហៅទីក្រុងថា កំពែង។ លោកប៉េលិយោត បានប្រែកាងពាងជូថា Vill Murée ក៏សមន័យថាកំពែងនេះដែរ។

**កានពូជី (ចិនទាជីវអាន : កាំព័រទី) :** ជាសំដីចិន កត់តាមសំដីខ្មែរ : កម្ពុជ រឺ កម្ពុជា។ ហេតុនេះហើយ បានជាចិនដែលសរសេរក្រោយជីវតាក្វាន់កែទៅជា កាំពូចេ ដែលនៅប្រើជាប់រហូតសព្វថ្ងៃនេះ។ ជីវតាក្វាន់ បានបញ្ជាក់ក្នុងសេចក្តីផ្តើមថា តាមការកត់ត្រារបស់ពួកអឺរ៉ុបថា ប្រទេសនេះឈ្មោះដូច្នេះដែរ។ ត្រង់នេះនាំអោយយើងដឹងថា ជីវតាក្វាន់ បានមើលសៀវភៅកំនត់ហេតុរបស់អឺរ៉ុប គឺពួកព័រទុយហ្គេ ដែលសរសេរឈ្មោះប្រទេសយើងថា Kambuja រឺ Kamvuja កម្វុជ (សូមមើលសៀវភៅ Le Cambodge។

**យុនលុន :** ឈ្មោះសមុទ្រ ដែលលោកជីវតាក្វាន់និយាយថា នៅតាមរយៈផ្លូវពីក្រុងចាម មកស្រុកចេនលា។ លោក ប៉េលិយោតស្រាជ្រាវឃើញថា ជាសមុទ្រកោះត្រលាច ដែលលោកប្រែ = Lamer de Poulo-Condor ប៉ុន្តែយើងស្រាវជ្រាវតាមរកអោយឃើញន័យច្បាស់ជាងនេះទៀតពុំទាន់ឃើញ។

**ចេនគាឡាង រឺ តាំងកេលាង :** ទំនងជាពាក្យសំស្ក្រឹត ស្រីគារដែលខ្មែរនិយមយកមកប្រើ ហៅពពួក ស្នំបរិវារ និង អ្នកបំរើស្តេច សំរាប់បែហបាម ជាលំអនិង កត្តិយសស្តេច។ យើងសរសេរសព្វថ្ងៃទៅជា «ស្រីង្គារ»។ មកពីដំបូងគេអានថា សឹងគារៈ មានសំលេង រៈ នៅចុងលុះចិនគ្មានអក្សរ រ ក៏យកសំលេង ឡ រឺ ល មកជំនួសបានជា សីការៈ ទៅជា ចេន គា ឡាង។

**ចេងផូវ រឺ ថេងភូ :** លោកជីវតាក្វាន់ ទុកជាឈ្មោះស្រុកមួយ ជាជាយដែនប្រទេសចេនលា។ លោកប៉េលិយោតបញ្ជាក់

ថែមថា ស្រុកនេះនៅត្រង់ភូមិភាគ Cap Saint-Jacques រឺ ខេត្តបារៀសព្វថ្ងៃនេះ។

ចេនលា រឺ ចេនលាក់ : ពាក្យនេះនៅក្នុងការរាវរកសំខាន់ណាស់ ព្រោះជាឈ្មោះប្រទេសតែម្តង។ នឹងថា ជាឈ្មោះដែលអ្នកស្រុកយើងហៅខ្លួនថា យើងជាអ្នកចេនលា រឺ ជាតិចេនលា ក៏មិនមែន ព្រោះដូចនិយាយខាងដើមសេចក្តីប្រែនេះស្រាប់ ដែលលោកជីវតាក្វាន់បញ្ជាក់ អ្នកប្រទេសនេះហៅខ្លួនអែងថា កាន់ ដៃ ចី ហើយដែលអ្នកស្រុកអឺរ៉ុបកត់ទុកថា កាំពូចី ដែលមានសំលេងស្រដៀងនឹង កាំពូចេ ដែរ។ កំនត់នេះបង្ហាញថា មិនមែនជនជាតិយើងដាក់ ឈ្មោះចេនលានេះទេ ប្រាកដជាបរទេសហៅសំគាល់តាមហេតុ រឺ តាមរបស់អ្វីមួយមិនខាន ពិសេសគឺចិននេះអែង បានមកទាក់ទងហើយបានសរសេរកត់ត្រាស្រុកយើងមុនគេ (តាំងពីសតវត្សទី៤) ។ បើដូច្នេះយើងត្រូវរាវរកតាមសំនៀងសំដីចិន តើចេនលានេះថាត្រាប់តាមសំដីខ្មែរថាម៉េច? អុទាហរណ៍ ពាក្យ ហ្វូហាន រឺ ហ្វូណាម មកពីត្រាប់ពាក្យខ្មែរថា ភ្នំ ចិនគ្មានអក្សរតំរួត ម្លោះហើយ ភ្នំ រំលែកសំលេងទៅជាភូណម រឺ ភូណាម។

កាលខ្ញុំទៅស្រុកចិន ជួបនឹងអ្នកស្រាវជ្រាវចចិនម្នាក់ ឈ្មោះស៊ីវម៉េង គាត់ប្រាប់ខ្ញុំថា គាត់ឃើញអែកសារមួយនិយាយពីឈ្មោះចេនលានេះ។ គឺដើមឡើយ ចិនហៅប្រទេសមួយ ដែលស្ថិតនៅខាងលើ ប្រទេសហ្វូណាន។ ប្រទេសនោះមានព្រៃក្រាស់ណាស់ ហើយសំបូរឃ្មុំយកក្រមួនធ្វើទៀន។ ពួកចិនតែងធ្វើដំនើរតាមសំពៅមកទិញដូរយកក្រមួនសុទ្ធ គឺក្រមួនយកពីឃ្មុំ ដើម្បីនាំទៅលក់អែស្រុកគេ សំរាប់ធ្វើទៀន ហើយគេនាំគ្នាសន្មតហៅស្រុកនេះថា : ក្រមួនសុទ្ធៗ គឺថា ចេន រឺ ចេង ប្រែថាសុទ្ធ អែឡា រឺឡាក់ ប្រែថា ក្រមួន រឺ ឃ្មុំ រឺ ទៀន (ភាសាចិនគេដាក់គុណនាមមុននាម) បូករួមមកបានន័យថា «ស្រុកក្រមួនសុទ្ធ»។ មានយោបល់មួយទៀតចុះសំរុងគ្នាថា នៅច្រកទន្លេធ្លាយទៅសមុទ្រ ជាកន្លែងអ្នកចេនលា នាំក្រមួនសុទ្ធទៅទុកលក់អោយសំពៅចិននោះ គេសន្មតឈ្មោះស្រុកក្រមួនដែរ គឺក្រមួនស (កម្ពុជាក្រោម) សនេះមិនសំដៅខ្លាញ់គោទេ ព្រោះសម័យនោះមិនទាន់មាន ដូច្នោះ សនេះគឺ ជាសុទ្ធនេះអែង ហើយនៅភូមិភាគក្រមួនសនេះ ក៏មានស្រុកភូមិមានឈ្មោះថា ក្រមួនៗច្រើនណាស់ នាំអោយសន្និដ្ឋានបានថា : ស្រុកភូមិត្រង់នោះជាទីឃ្លាំងផ្ទុកក្រមួន នាំទៅទុកលក់អោយសំពៅចិនមែន ព្រោះសំពៅដើរតែតាមសមុទ្រ មិនបានចូលមកតាមទន្លេទេ។

ឆីនថា រឺ ឆេនថាន់ : ទំនងមកពីពាក្យ ជាន់ឋាន ក្រែងក្នុងពិធីនេះគេនាំលោកមកកាន់ទីកន្លែងរបស់កូនស្រី? ប៉ុន្តែក្នុងទំនៀម ហើយមកអិលូវនេះមិនឃើញមានធ្វើដូច្នេះទេ។ ពត៌មាននេះ មិនគួរនឹងជឿ ប៉ុន្តែយើងយល់ថា តើលោកជីវតាក្វាន់បំផ្លើសរឿងនេះដើម្បីប្រយោជន៍អ្វី? មិនតែប៉ុណ្ណោះ លោកបញ្ជាក់ទាំងពេលដែលឃើញគេធ្វើ ហើយត្រង់ណាលោកមិនឃើញផ្ទាល់ភ្នែកដូចជានៅក្នុបន្ទាប់ក៏លោកបញ្ជាក់ច្បាស់ថា លោកគ្រាន់តែលឺគេថាទេ (ត្រង់នេះឃើញថា

លោកមានចិត្តត្រង់ណាស់ក្នុងដំនើរកត់ហេតុនេះ។

ឆេណាំ រឺ ឆាណាំ : ជាសំលេងចិន ត្រាប់តាមពាក្យខ្មែរឆ្នាំង ដោយសារចិនគ្មានសំលេងអក្សរតំរួត គឺសំដៅយក កំពង់ឆ្នាំង ព្រោះពាក្យកំពង់ប្រែថា ភូមិ ម្ល៉ោះហើយ លោកជីវតាក្វាន់កត់យកតែឈ្មោះភូមិតែម្តង។ ច្បាស់ថែមពីលើនេះទៀត គឺ លោកជីវតាក្វាន់បានរាប់រៀបថា ជាឈ្មោះខេត្តមួយនៃប្រទេសចេនលា ហើយគេធ្វើដំនើរចេញពីនេះ ត្រូវឆ្លងកាត់សមុទ្រសាប (ទន្លេសាប) អស់ពេលដប់ថ្ងៃទៀត ទើបដល់ក្រុងធំ។

ផូគូ : ក្លាយតាមសំដីចិន ទំនងជាហៅពាក្យខ្មែរ ចៅគូ ដែលគេធ្លាប់និយមប្រើនៅចុងសតវត្សទី១៣ សំរាប់ហៅលោកសង្ឃ (សព្វថ្ងៃសៀមនៅប្រើនៅឡើយ)។

ប៉ាតេង : ពាក្យខ្មែរបុរាណ ម្រតេង ដែលក្រោយមកក្លាយជា កំរតែង រួចសព្វថ្ងៃថា គំដែង គឺសំរាប់សំគាល់ងារមន្ត្រីជាន់ខ្ពស់ និង អ្នប្រាជ្ញធំ រឺ អ្នកមានរិទ្ធតេជៈខ្លាំងក្លា។ សព្វថ្ងៃនៅប្រើចំពោះព្រះសង្ឃ អុទាហរណ៍ : បពិត ព្រះគំដែងសង្ឃ ទាំងឡាយ ជាដើម។

ប៉ាធ : ទំនងជាត្រប់តាមសំលេងអ្នកស្រុកដើមហៅថា ប៉ាតូវ។ លោកប៉េលិយោត បញ្ជាក់ថា សព្វថ្ងៃជានជាតិចារាយនៅប្រើពាក្យ ប៉ាតូវ ហៅអូវពុកនៅឡើយ។

ប៉ានឃាប រឺ ប៉ានឃីត : ទំនងជាត្រាប់សំលេងខ្មែរ បណ្ឌិត (ដែលយើងអានក្លាយទៅ បន្ទីត រឺ អន្ទិត សំដៅយកពួកអ្នកប្រាជ្ញ។

ប៉ាវទៀងកាក : តាមសេចក្តីក្នុងអត្ថបទ លោកជីវតាក្វាន់ ហៅសំគាល់អង្គរ។ មកពីពាក្យអង្គរ បុរាណយើង ហៅវង្គរមានប្រើក្នុងសិលាចារឹកជាច្រើន។

ប៉ាស៊ីវ៉ី : សំស្ក្រឹត បស្វី ប្រែថាអ្នកមានតបៈ គឺខ្មែរបុរាណហៅពពួកអ្នកបួសជាតាបសនៅតាមព្រៃ ច្រើនអ្នកប្រតិបត្តិតាមគម្ពីរវេទ (សូមមើលក្នុងរឿងរាមកេរខ្មែរ គេប្រើពាក្យនេះសំរាប់ពួកយក្សហៅព្រះរាម ដែលធ្វើតបៈក្នុងព្រៃថា បស្វី។

ផេង កេស៊ី : លោកជីវតាក្វាន់ថា ផេងកេស៊ី ជារុក្ខជាតិដែលគេយកស្លឹកវាមកធ្វើស្រា។ យើងបានប្រទះឃើញក្នុងវចនានុក្រមខ្មែរភាគ១ ទំព័រ ៨២៩ និយាយថា ខ្មែរយើងជាន់ដើមគេយកស្លឹកឈើម្យ៉ាងមកធ្វើស្រា ហៅថា ស្លឹកភ្នាស។ ភ្នាស

នេះជាឈើព្រៃ មានសំបកក្រមរជ្រួញៗ ស្លឹកល្អិតរឹង ផ្កាល្អិតកញ្ចុំ ពណ៌ស្វាយ។ ដូច្នេះគឺស្លឹកភ្ញាស នេះហើយ ដែលកត់តាមសំលេងចិនទៅជាផេកេស៊ី។

ពុទ្ធៃ្យ : សំស្រ្កឹត ព្រះ ប្រែថា ប្រសើរ គឺតាមនិយមន័យខ្មែរសំរាប់ហៅបុគ្គលជាទីគោរព មានព្រះពុទ្ធអង្គជាដើម ។ ក្រោយមកគេហៅមន្រ្តីមានសក្តិខ្ពស់ រឺ សង្ឃដែលមានសមណសក្តិ។

ពូលូវរឺ ពូលូឈិង មកពីពាក្យផ្លូវ ដែលចិនគ្មានសំលេងអក្សរតំរួត ក៏អានទៅជាពីរព្យាង្គថា ពូលូវ ។អែពាក្យឈិង ជាពាក្យចិនប្រែថា ភូមិ ដូច្នេះ ពាក្យនេះមានន័យថា ភូមិផ្លូវ ទំនងជា «ភូមិផ្លូវត្រី សព្វថ្ងៃទេដឹង? ព្រោះអត្ថបទនេះ និយាយពីភូមិនៅមាត់ទន្លេសាប តាមរយៈដំនើរទៅសៀមរាប។

ភុយទ្បាំង : លោកប៉េលិយោត លោកពន្យល់ពាក្យនេះថា C'est le non d'une barque faite seule pièce de bois, l'original plan? piran n'est pas cnnu ចំពោះយើង យល់ថា ទំនងជាទូកកំរោល ដែលគេលុងធ្វើពីឈើមួយដើម ប៉ុន្តែមិនដឹងជាឈ្មោះដើមថាម៉េច បានជាចិនកត់ជាពាក្យហៅផុយទ្បាំងនេះ។

ម៉ែ រឺ មី :ជាពាក្យសំរាប់មនុស្សស្រ្តី រឺ សំរាប់ហៅម្តាយដែលចិនខំថាតាមសំលេងខ្មែរមេ។ អុទាហរណ៍ មេជ្រូក មេគោ មេបា...។

សាមប៉ា : ចិនអានតាមសំលេងខ្មែរថា សំពះ។

ស៊ុនណា : លោក ប៉េលិយោត ដាក់ក្នុងវង់ក្រចកអានថា Siennaja ហើយលោកពន្យល់ន័យថា L'original de ce nom de bateau, quelque chose comme senda, n'a pas éteé retrouvé តាមមតិយើង គឺជាទូកម្យ៉ាង ដែលគេយកបន្ទះក្តារមកវាយភ្ជាប់ភ្ជិតគ្នា គេច្រើនហៅសព្វថ្ងៃថា ទូកឡើងក្តារ បុរាណហៅថាទូកសន្តរ។ ទំនងជា សន្តរ នេះហើយដែលចិនកត់ទៅជាស៊ីនណា។

ស៊ីលាក់ទី : មកពីពាក្យសំស្រ្កឹត ស្រិស្ទិន រឺ ស្រិស្ទី ប្រែថា អ្នកទ្រទ្រង់ នូវស្រុតិ គឺពួកអ្នកចេះដឹង រឺ អ្នកមានប្រាជ្ញា។

ហ៊ុតឈឹង : ពាក្យនេះ មកពីភាសាចិន : ហ៊ុត = ព្រះពុទ្ធ + ឈឹង = ភូមិព្រះពុទ្ធ។ លោក ប៉េលិយោត យល់ថាជាភូមិពោធិសាត់ ប៉ុន្តែ បើតាមកំនាព្យលោកសុតន្តប្រីជាអិន្ទ និវាសអង្គរវត្ត លោកនិយាយដំនើរលោកទៅអង្គរវត្តតាមមាត់ទន្លេ

សាប ឃើញភ្នំមួយនៅពាក់កណ្ដាលផ្លូវនេះឈ្មោះថា ភ្នំត្រៃភព។ ហើយគាត់ពិចារណាថា នរណាយកពាក្យត្រៃភពមក ដាក់ឈ្មោះ ជានាមរបស់ព្រះពុទ្ធដែរ ដូច្នេះហ៊ុឈឹង គឺជាភ្នំត្រៃភពនោះអែង។